April-2009.qxd 3/25/2009 4:06 PM Page 1


# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ២០


CSC ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

## មាតិកា




ការសាយភាយនៃការពិសាគ្រឿងស្រវឹង ទំព័រ ៥



១៣ឆ្នាំ ចំពោះបេសកកម្មជាគ្រីស្តទូត... ទំព័រ ៩



កតញ្ញូកូនខ្មែរពេលចូលឆ្នាំថ្មី ទំព័រ ១៧


# សាលាក្តីខ្មែរក្រហមដំណើរការរហូត តែពលរដ្ឋខ្លះមិនបានដឹង



សាលាក្តីខ្មែរក្រហមកំពុងដំណើរការជំនុំជម្រះរឿងក្តីរបស់អតីតមេដឹកនាំខ្មែរក្រហមបំនួន ៥រូប និងទោះបីសាលាក្តីនេះកំពុងជួបប្រទះនូវវិបត្តិថវិកា ប៉ុន្តែពលរដ្ឋខ្មែរក្រីក្រមួយចំនួនដែលជាជនរងគ្រោះពីរបបនេះ នៅតែមិនដឹងថា តុលាការកំពុងតែដំណើរកាត់ទោសនេះនៅឡើយទេ។

ទំព័រទី១០_១១


SIPAR

សៀវភៅធ្វើអោយអ្នកចេះ

មានលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅនានា

023 216 001
siparedition@online.com.kh





កម្មវិធីវិទ្យុ



អេម៉ាន្នូអែល សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

April-2009.qxd 3/25/2009 4:06 PM Page 2






Photo : Caritas

អង្គការការីតាសអាស៊ី និងការីតាសកម្ពុជា រៀបចំសិក្ខាសាលាលើកទីពីរអំពី "ការត្រៀមបង្ការគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍" ដែលណែនាំដោយលោកឃ្យូដ ហែនរីក ទីប្រឹក្សាការីតាសនៅអាស៊ីផ្នែកគ្រោះមហន្តរាយ កាលពីថ្ងៃទី ២៥-២៧ ខែមីនា ឆ្នាំ២០០៩ នៅអាសយដ្ឋានការីតាសក្រុងភ្នំពេញ **(ឆ្វេង)**

ការកាច់នំប៉័ងដែលជាតំណាងព្រះកាយព្រះកាយព្រះគ្រីស្ត និងផឹកស្រាទំពាំងបាយជូរ តំណាងព្រះលោហិតព្រះអង្គក្នុងពិធីអភិបូជាមួយក្នុងរដូវអប់រំពិសេសនៅព្រះសហគមន៍សន្តយ៉ូសែប ភ្នំពេញ កាលពីថ្ងៃទី៨ ខែមីនា **(ក្រោម)**





ក្នុងពិធីអភិបូជា ទោះបីលោកបូជាចារ្យបរទេសក៏លោកអង្គុយតាមទំនៀមទម្លាប់ជនជាតិខ្មែរដើម្បីថ្វាយការគោរពដល់អង្គព្រះគ្រីស្ត **(លើ)**



យុវនារីនៅព្រះសហគមន៍កាតូលិក ភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវពិនិត្យមើលសរសៃសូត្រដោយផ្ចិតផ្ចង់មុននឹងត្បាញ **(ស្តាំ)**

យុវនារីនៅព្រះសហគមន៍ចំការទៀង ជួយគ្នារវិញអំបោះសូត្រទៅក្នុងត្រល់ដើម្បីទុកត្បាញជាក្រណាត់នៅពេលក្រោយ។ សកម្មភាពនេះធ្វើឱ្យនឹកដល់ការយកចិត្តទុកដាក់របស់ព្រះសហគមន៍ចំពោះអាជីបយុវនារីនៅជនបទ **(ឆ្វេង)**



Photos : S. Philong





# ចងចាំប្រវត្តិសាស្ត្រ ទុកជាមេរៀនទៅអនាគត



Photo : L. Samphors

លោកលី សុវណ្ណា ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)

កាលពីថ្ងៃ១៤ មីនាកន្លងទៅនេះ ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក រៀបចំសិក្ខាសាលាមួយអំពីរបបខ្មែរក្រហម។ យើងស្តាប់ការបកស្រាយពន្យល់ពីគ្រីស្តបរិស័ទដែលបានឆ្លងកាត់សម័យនោះទាំងខ្មែរ និងបរទេស។

លោករ៉ាម៉ូស ជាអតីតលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានគូសបញ្ជាក់អំពីបទពិសោធន៍ផ្ទាល់ របស់លោក ដែលឃើញទិដ្ឋភាពនៃការកាប់សម្លាប់ និងធ្វើទារុណកម្មលើប្រជាជនស្លូតត្រង់រាប់លាននាក់ ក្នុងអំឡុងដើមសម័យកាលខ្មៅងងឹតនៃរបបខ្មែរក្រហម។ ចំណែកលោកបូជាចារ្យប្រាំងស្វ័រ ប៉ុងសូដ៏ ក៏ជាសាក្សីមួយយ៉ាងសំខាន់ចំពោះរបបខ្មែរប្រហមផងដែរ។ លោកជាអ្នកសរសេរសៀវភៅប្រវត្តិសាស្ត្រខ្មែរពិសេសអំពីរបបនេះ។ ហើយលោកជាអ្នកដំបូងគេបង្អស់ដែលបានប្ដឹងតវ៉ាអំពីអំពើកាប់សម្លាប់នៅក្នុងរបបខ្មែរប្រហមទៅសហគមន៍អន្តរជាតិទៀតផង។

សម្រាប់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា យើងតែងប្រឆាំងដាច់ខាតរាល់ទង្វើរំលោភសិទ្ធមនុស្ស ពិសេសប្រឆាំងនូវរាល់សកម្មភាពទាំងឡាយណា ដែលគំរាមកំហែងដល់ជីវិតប្រជាជន។ ការកាប់សម្លាប់ជាអំពើដ៏គួរឱ្យស្អប់ខ្ពើមបំផុត និងឃ្លៀតឆ្ងាយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

សម្រាប់ក្នុងខែនេះ អ្នកនាំសារ បង្ហាញអំពីប្រធានបទទាក់ទងនឹងរបបខ្មែរក្រហម។ ដូច្នេះសូមឱ្យយុវជន យុវនារីទាំងអស់ស្វែងយល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ ដែលទើបតែបញ្ចប់នាប៉ុន្មានទសវត្សចុងក្រោយនេះ ព្រោះបើប្រទេសមួយបំភ្លេចនូវប្រវត្តិសាស្ត្រខ្លួន ប្រវត្តិសាស្ត្រនោះ នឹងប្រាកដជាអាចកើតឡើងវិញ ពិសេសប្រវត្តិសាស្ត្រនៃភាពខ្មៅងងឹត។ យើងទាំងអស់គ្នាត្រូវបើកចិត្តគំនិត និងរៀនសូត្របន្ថែមទៀតអំពីព្រឹត្តិការណ៍នេះដើម្បីដឹងថា តើធ្វើយ៉ាងម៉េចកុំឱ្យរឿងដូចនេះកើតមានម្តងទៀត ទន្ទឹមនឹងធ្វើឱ្យសង្គមរបស់យើងមានការរួបរួមគ្នា ចេះសម្រុះសម្រួលគ្នា ព្យាបាលផ្លូវចិត្ត និងក៏ផ្តល់យុត្តិធម៌ចំពោះអ្នកដែលបានស្លាប់ទៅនោះផងដែរ?

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org

ប្រធាន : លោកលី សុវណ្ណា។
អនុប្រធាន : កញ្ញាកែវ កញ្ញា។ អ្នកសម្របសម្រួល : លោកប៉ូល រឿង ឆត្រឆ័យ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

**សេវាកម្មជាទីគាប់ចិត្ត!** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ ទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។ **សូមអរគុណ!**

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

### កម្មវិធីអេម៉ាន្វូអែល {សម្លេងពីព្រះសហគមន៍កាតូលិក} ប្រចាំខែមេសា

អត្ថបទព្រះគម្ពីរដំណឹងល្អ និងភ្ញៀវកិត្តិយសចូលរួមអត្ថាធិប្បាយមានដូចតទៅ :

-ថ្ងៃសៅរ៍ទី៤ : អត្ថបទគម្ពីរដំណឹងល្អថ្ងៃអាទិត្យ បុណ្យដែលព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម (ម៉ាកុស ជំពូក ១៤, ៩១ ដល់ជំពូក ១៥, ៩១៧) ចូលរួមពន្យល់ដោយលោកបូជាចារ្យសេរ៉ាល់ វ៉ូហ្សាំង ពីព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

-ថ្ងៃសៅរ៍ទី១១ : អត្ថបទគម្ពីរដំណឹងល្អសម្រាប់បុណ្យចម្លង បកស្រាយដោយលោកអែនរីកេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

-ថ្ងៃសៅរ៍ទី១៨ : អត្ថបទគម្ពីរដំណឹងល្អ (យ៉ូហាន ជំពូក ២០, ៩១៩-៣១) ដែលពន្យល់ដោយលោកប្រ៊ុយណូ កូសម៉ី ជានាយកទេវវិទ្យាល័យកម្ពុជា។

-ថ្ងៃសៅរ៍ទី២៥ : អត្ថបទគម្ពីរដំណឹងល្អ (លូកា ជំពូក២៤, ៩ ៣៥-៤៨) ដែលចូលរួមពន្យល់ដោយលោកអ៊ុន សុន ជាបូជាចារ្យប្រចាំព្រះសហគមន៍កាតូលិកតំបន់កំពត។

### កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក" (FM 99.5 Mhz) ប្រចាំខែមេសា

ថ្ងៃទី០៦ មេសា : ទិដ្ឋភាពក្នុងគុកទួលស្លែង។ ថ្ងៃទី០៧ មេសា : ពិធីបុណ្យចូលឆ្នាំខ្មែរ។ ថ្ងៃទី២០ មេសា : ស្នេហាតាមទីសាធារណៈ។ ថ្ងៃទី២១ មេសា : ហេតុអ្វីអ្នកត្រូវធ្វើការសម្រេចចិត្ត? ថ្ងៃទី២៧ មេសា : វិធីបញ្ចៀសការយល់ច្រឡំ។ ថ្ងៃទី២៨ មេសា : ដំណោះស្រាយនៅពេលមានការអូសទាញ។ ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញ។ **សូមកុំភ្លេចស្តាប់!**

## សេដ្ឋកិច្ច

# កម្មករកាត់ដេរ២០០០០នាក់ បាត់ការងារ

**ខាន់ ភីរម្យ**

សមាគមរោងចក្រកាត់ដេរ នៅកម្ពុជា អះអាងថា បណ្តារោងចក្រក្នុងប្រទេសកំពុងតែប្រឈមមុខនឹងការធ្លាក់ចុះនៃការបញ្ជាទិញពីបរទេសនាខណៈពេលដែលវិបត្តិហិរញ្ញវត្ថុ នៅមិនទាន់ត្រូវបានដោះស្រាយ ។ ការបញ្ជាទិញនូវផលិតផលកាត់ដេររបស់កម្ពុជានៅក្នុងខែកុម្ភៈ បន្តធ្លាក់ចុះ ។ សមាគមនេះក៏បានបញ្ជាក់ថា : "ចាប់ពីខែមករា ឆ្នាំ២០០៩ ការបញ្ជាទិញមានការថយចុះត្រឹមតែ៣០%ទេ តែមកដល់ខែកុម្ភៈ បានថយចុះពី១០ ទៅ១៥%ទៀត" ។


Photo : S. Philong

ពាក់ព័ន្ធនឹងបញ្ហានេះ កាលពីដើមខែមីនាកន្លងទៅនេះ លោកចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក៏បានអះអាងអំពីការធ្លាក់ចុះនេះដែរ ។ លោកបានបញ្ជាក់ផងដែរថា : "ប្រាក់ចំណូលពីវិស័យកាត់ដេរកាលពីខែមករា ទទួលបានត្រឹមតែ ៧០លានដុល្លារទេ ខណៈដែលកាលពីខែមករា ឆ្នាំ២០០៨ គឺយើងទទួលបានរហូតដល់ ២៥០លាន ដុល្លារឯណោះ" ។ រហូតមកដល់ពេលនេះ វិស័យកាត់ដេរគឺជាប្រភពប្រាក់ចំណូល និងក៏ជាប្រភពការងារដ៏សំខាន់របស់ប្រជាជនក្រីក្រ ។ នៅឆ្នាំ២០០៨ គេជឿថា វិស័យនេះអាចផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណជា ៣០០០០០នាក់ តែបើតាមរបាយការណ៍ថ្មីៗ បានឱ្យដឹងថា រោងចក្រមួយចំនួនកំពុងប្រឈមមុខនឹងការបិទទ្វារដោយសារតែវិបត្តិហិរញ្ញវត្ថុ ។

ចំណែកលោកវង សូត្រ រដ្ឋមន្ត្រីក្រសួងការងារ អះអាងថា តាំងតែពីមករា ដល់ខែមីនា នាឆ្នាំ២០០៩ នេះ កម្ពុជាមានរោងចក្រជាច្រើនបានបិទទ្វា តែក៏មានរោងចក្របើកថ្មីដែរ ដោយគ្រាន់តែមិនតុល្យ-ភាព ជាហេតុធ្វើឱ្យកម្មករ-កម្មការិនី ជាច្រើននាក់ត្រូវប្រឈមមុខនឹងការអត់ការងារធ្វើ ។ លោករដ្ឋមន្ត្រី មានប្រសាសន៍ឱ្យដឹងទៀតថា រោងចក្រដែលបិទគឺមានរហូតដល់ទៅ៩៩ ប៉ុន្តែបើកវិញប្រមាណជា ៧៨តែប៉ុណ្ណោះ ។ នេះជាហេតុធ្វើឱ្យមានកម្មករកម្មការិនីត្រូវអត់ការងារធ្វើប្រមាណជា ២០០០០ នាក់ ។ ការបាត់បង់ការងារ គឺជាបញ្ហាមួយសម្រាប់សង្គមកម្ពុជា ប៉ុន្តែវាមិនមែនបញ្ហាធ្ងន់ធ្ងរទេ ។

### ប្រាក់ខែកម្មករ ត្រឹម ៧៩ ដុល្លារប៉ុណ្ណោះ

ការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងដោយវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍បានឱ្យដឹងថា ឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជាអាចផ្តល់ប្រាក់ឈ្នួលដល់កម្មករ និងកម្មការិនីក្នុងមួយខែជាមធ្យម ៧៩ដុល្លារ តែប៉ុណ្ណោះ។ លោកបណ្ឌិតកង ចន្ទតារារ័ត្ន ប្រធានវិទ្យាស្ថាននេះ បានឱ្យដឹងថា ប្រាក់ខែនេះ ថ្វីត្បិតតែអាចឱ្យពួកគេរស់បាន តែវាមិនសមរម្យនឹងកម្លាំងពលកម្មដែលពួកគេបានធ្វើនោះទេ។ ជាមួយនឹងប្រាក់ខែនេះ ជាទូទៅពួកគេម្នាក់ៗត្រូវ ចំណាយទៅវិញស្ទើរតែទាំងអស់សម្រាប់ថ្លៃជីវភាព ពោលគឺកម្មករម្នាក់ត្រូវចំណាយសរុបជាមធ្យម គឺ៧២ដុល្លារ ក្នុងមួយខែ ដោយក្នុងនោះ ៥៧ដុល្លារ សម្រាប់ថ្លៃម្ហូបអាហារ ជួលផ្ទះ ទឹកភ្លើង និងសម្លៀកបំពាក់ ចំណែក១៥ដុល្លារទៀត គឺសម្រាប់ផ្ញើទៅគ្រួសារនៅជនបទ"។

លោកចាន់ សុផល ដែលជាប្រធានសមាគមសេដ្ឋ-កិច្ចកម្ពុជាបានឱ្យដឹងថា ការបាត់បង់ការធ្វើនេះមិនបណ្តាលឱ្យកម្ពុជា មានវិបត្តិធ្ងន់ធ្ងរឡើយ គឺដោយសារតែវិស័យកសិកម្មកំពុងតែខ្វះខាតមនុស្ស ។

## សុខភាព

# ទឹកមានសារៈសំខាន់ណាស់ ប៉ុន្តែទឹកមិនស្អាតអាចបំផ្លាញជីវិត

**ជាត សំភី**

តាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ហែម សុខហន បានឱ្យដឹងថា :

ទឹកមានសារៈសំខាន់ណាស់សម្រាប់ជីវិត មិនថាតែមនុស្ស សត្វ ឬរុក្ខជាតិឡើយ ។ បើគ្មានទឹក គឺគ្មានជីវិត ។ នៅក្នុងរាងកាយមនុស្ស គឺពោរពេញដោយជាតិទឹក ។ កុមារមានជាតិទឹក ពី ៥៥% ទៅ ៦០% នៃទម្ងន់ខ្លួន ។ ស្ត្រីមានជាតិទឹក ៥៥% នៃទម្ងន់ខ្លួន ហើយបុរសមានជាតិទឹក ៦៥%នៃទម្ងន់ខ្លួន ។


Photo : P. Samphy

ទឹកមានសារៈសំខាន់ ។ ប៉ុន្តែបើយើងប្រើប្រាស់ទឹកមិនស្អាត វាបណ្តាលឱ្យយើងមានជម្ងឺដែលពេលខ្លះអាចដល់ស្លាប់ផង ។

ខ្លួនប្រាណមនុស្ស ត្រូវការទឹកដែលគ្មានមេរោគ គឺទឹកស្អាតដែលមានគុណភាព ។ ប្រសិនបើបរិភោគទឹកមិនស្អាត និងមានមេរោគ មនុស្សអាចកើតជំងឺផ្សេងៗ ដូចជាជំងឺអាសន្នរោគ រាគមួល គ្រុនពោះ-វៀន រលាកថ្លើម និងដង្កូវពោះវៀន-ល- ។

ប្រភពទឹកដែលយើងអាចយកមកប្រើប្រាស់បានគឺមានពីរ ។ ទី១ទឹកនៅក្រោមដី ពោលគឺទឹកអណ្តូងដែលគ្មានជាតិអាសេនិច និងត្រូវសង់ឆ្ងាយពីកន្លែងកខ្វក់ដូចជាបង្គន់ ។ ទីពីរប្រភពទឹកទន្លេ ស្ទឹង ព្រែក បឹងបួរ ស្រះត្រពាំង ដែលមិនមានវត្ថុសៅហ្មង ហូរចូល ដូចជាលាមកសត្វមនុស្ស ឬសំរាមជាដើម ។

លោកវេជ្ជបណ្ឌិតក៏សង្កត់ធ្ងន់ថា ទោះបីជាទឹកយកមកពីប្រភពណាក៏ដោយ ទឹកសម្រាប់ផឹកត្រូវតែដាំឱ្យបានពុះ និងទុកឱ្យពុះយ៉ាងហោចណាស់ ១០នាទីទើបទឹកនោះមានសុវត្ថិភាព ។

រាងកាយនៃមនុស្សត្រូវការទឹកបរិមាណគ្រប់គ្រាន់តាមកាលៈទេសៈណាមួយ ។ តួយ៉ាង គឺពេលស្រេកយើងត្រូវការផឹកទឹកមួយចម្អែត ។ ក្នុង១ថ្ងៃ យើងត្រូវការទឹកពីពីរទៅបីលីត្រ ព្រោះទឹកអាចបាត់បង់តាមនិយាយស្តី បែកញើស ឬបន្ទោរបង់-ល- ។



## យុវវ័យ


Photo : S. Philong

# ការសាយភាយនៃការពិសាគ្រឿងស្រវឹង

**ខាន់ ភីរម្យ**

កំណើននៃការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមយុវជន ត្រូវបានគេអះអាងថា កំពុងមានការកើនឡើង ។ នេះបើតាមការសន្និដ្ឋានរបស់អ្នកសម្របសម្រួលនៃក្រុមប្រឹក្សាយុវជនកម្ពុជា ។

កញ្ញាម៉ៅ ពុទ្ធារ័ត្ន ជាអ្នកសម្របសម្រួលរបស់ក្រុមប្រឹក្សាយុវជនកម្ពុជា មានប្រសាសន៍ថា សញ្ញាណនៃការកើនឡើងនេះ គឺស្តែងឡើងយ៉ាងច្បាស់តាមរយៈការកើនឡើងរបស់ចំនួនក្លឹប និងកន្លែងកំសាន្តនានានៅតាមទីក្រុង និងតាមទីប្រជុំជន នៅទូទាំងប្រទេស ។ កញ្ញាបន្ថែមដែរថា ក្រុមប្រឹក្សាយុវជនកម្ពុជាមិនមានទិន្នន័យលើបញ្ហានេះទេ ប៉ុន្តែយើងអាចសន្និដ្ឋាន ទៅតាមរយៈការកើនឡើងនៃសេវាកំសាន្តនៅក្នុងប្រទេស និងត្រូវបានគេ ផ្សព្វផ្សាយយ៉ាងចំហ ។ កញ្ញាបញ្ជាក់ថា : "តាមរយៈការផ្សព្វ-ផ្សាយនានា ខ្ញុំមើលឃើញថា សេវាកំសាន្តសម្រាប់យុវជននៅប៉ុន្មានឆ្នាំនេះ គឺមានការកើនឡើងច្រើនមែនទែន" ។ កញ្ញាបន្តទៀតថា កន្លែងទាំងនោះ គឺជាជម្រុកទាក់ទាញឱ្យយុវជនប្រើប្រាស់ទាំងគ្រឿងស្រវឹង និងបើអាច ទាំងគ្រឿងញៀនផងដែរ ។

ក្រៅពីអ្នកជំនាញដែលធ្លាប់ធ្វើការជាមួយនឹងយុវ-ជននោះ ប្រជាជនម្នាក់នៅក្នុងស្រុកបសេដ្ឋ ឯខេត្តកំពង់ស្ពឺ បានមើលឃើញពីកំណើននៃការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងចំណោមយុវជនផងដែរ ។ លោកស្រី រ៉ាត់ មានប្រសាសន៍ដែរថា : "ការផឹកស៊ីសប្បាយ គឺកំពុងតែក្លាយទៅជាទម្លាប់មួយ របស់យុវជនក្មេងៗទៅហើយ នៅពេលនេះ" ។

លោកស្រីបានឱ្យដឹងថា យុវជននៅតាមទីក្រុង គេផឹកស៊ីសប្បាយទៅតាមស្ថានភាពរបស់គេជាអ្នកទីក្រុង ។ ចំណែកអ្នកនៅក្នុងស្រុកភូមិរបស់គាត់វិញ គេផឹកស៊ីសប្បាយ តាមរយៈមធ្យោបាយរបស់ពួកគេដែរ ។ ប៉ុន្តែអ្វីដែលដូចគ្នានោះគឺភាពស្រវឹង និងអំពើផ្តេសផ្តាសរបស់ពួកគេ ។ លោកស្រី ក៏បញ្ជាក់បន្ថែមថា : "ខ្ញុំឃើញនៅទីក្រុង យុវជនចូលចិត្តទៅចូលកន្លែងមានភ្លើងពណ៌ និងផឹករបស់ល្អៗ ។ ប៉ុន្តែនៅតាមជនបទ គេអាចផឹកស្រាស ឬទឹកត្នោតជូ ។ ប៉ុន្តែដល់ពេលដែលស្រវឹង គេច្រើនតែប្រព្រឹត្តអំពើហិង្សា និងអំពើអសីលធម៌ជាច្រើន" ។

សម្រាប់កញ្ញាពុទ្ធារ័ត្នវិញយល់ឃើញថា ការស្រវឹងនេះ នឹងនាំមកនូវគ្រោះថ្នាក់ច្រើនដល់យុវជន និងប្រទេសជាតិ ។ គ្រឿងស្រវឹងគឺអាចជំរុញឱ្យពួកគេស្វែងរកសេវាផ្លូវភេទ ដែលមិនមានសុវត្ថិភាព ជាហេតុនាំឱ្យពួកគេប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺអេដស៍ ។ ភាពស្រវឹងគឺអាចឱ្យពួកគេបាត់បង់ម្ចាស់ការលើការបើកបរ និងអាចធ្វើឱ្យពួកគេ ជួបប្រទះគ្រោះថ្នាក់ចរាចរណ៍ ។ ហើយការផឹកគ្រឿងស្រវឹងក៏អាចជាយាននាំឱ្យពួកគេប្រើប្រាស់គ្រឿងញៀន និងធ្វើឱ្យអ្នកខ្លះ ក្លាយទៅជាជនអសីលធម៌សង្គម ដោយហ៊ានប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ដូចជាចាប់រំលោភនារីភេទជាដើម ដែលនេះធ្វើឱ្យពួកគេក្លាយទៅជាឧក្រិដ្ឋជន ។

កញ្ញាសង្កត់ធ្ងន់ថា យុវជនជាស្នូលរបស់ជាតិ ប៉ុន្តែបើពួកគេមានបញ្ហានោះ តើឱ្យជាតិរំពឹងអ្នកណា? តើប្រទេសអាចមានការអភិវឌ្ឍន៍បានទេ ?

ដោយឆ្លើយតបនឹងចំណោទបញ្ហាខាងលើនេះ យុវ-ជនមួយរូបដែលជានិស្សិត នៅឯសកលវិទ្យាល័យភូមិន្ទភ្នំពេញ អះអាងថា ការទទួលទានស្រវឹង មិនបណ្តាលឱ្យមានបញ្ហានោះទេ ។ តែវាជាស្ពានមួយសម្រាប់បង្កើតទំនាក់ទំនង ឱ្យទូលំទូលាយ ។ ប៉ុន្តែរូបគេក៏ទទួលស្គាល់អំពីគ្រោះថ្នាក់នៃគ្រឿងស្រវឹងដែរ ។ គេអះអាងថា : "បើគេហៅ យើងមិនទៅ វាជាបញ្ហា ។ តែបើយើងទៅហើយ មិនចេះគិត ចេះតែផឹករហូតដល់ស្រវឹងនោះ ក៏វាជាបញ្ហាដែរ" ។

April-2009.qxd 3/25/2009 4:07 PM Page 6



# វិធីដាំដំណាំត្រប់វែងឱ្យបានផ្លែច្រើន

**ទស្សនាវដ្ដីកសិករ លេខ ១០៩**



Photo : L. Samphors

ខាងក្រោមនេះ ជាបទពិសោធន៍នៃការដាំត្រប់វែង របស់អ្នកមីងវី សំណាង អាយុ ៣៤ឆ្នាំ រស់នៅឃុំកោះប្រាក់ ស្រុកកៀនស្វាយ ខេត្តកណ្ដាល:

**១. ការរៀបចំដី**

មុននឹងដាំ យើងភ្ជួររាស់ដី ១ ឬ២ ដង និងដកយកស្មៅចេញ។ យើងដាក់ជីទ្រាប់បាតលាមកសត្វក្នុងបរិមាណ០,៨គីឡូក្រាម សម្រាប់ដី ១ម៉ ( ជីកកប់បញ្ចូលក្នុងដី) ។បន្ទាប់មកហាលដីចោលរយៈពេល ៥ថ្ងៃ ឱ្យដីស្ងួតល្អ រួចលើករងដែលមានបណ្ដោយ ៤ម៉ែត្រ ទទឹង ៣តឹក និងកម្ពស់មួយតឹក។

**២. របៀបដាំ**

នៅលើរងយើងកាប់រណ្ដៅដាំដោយមានចន្លោះគុម្ព ៤តឹក។ មុនពេលដាំយើងយកគ្រាប់ពូជត្រាំទឹកក្ដៅឧណ្ហៗ រួចផ្អាប់ទុករយៈពេល ២ យប់ ៣ថ្ងៃ។ ក្នុង១គុម្ព យើងដាក់គ្រាប់ដាំ ៣ ឬ៥គ្រាប់ បន្ទាប់មកគ្របចំបើងគ្របពីលើ និងស្រោចទឹក ឱ្យជោគល្អ។ ពេលដាំបានប្រហែល ៧ថ្ងៃ ត្រប់ក៏ចាប់ដុះពន្លក។

**៣. ការថែទាំ**

ក្រោយពីត្រប់ដុះពន្លកបាន ១អាទិត្យ យើងក៏ចាប់ផ្ដើមជ្រុំគល់ត្រប់ ដករំលោះយកកូនចេញខ្លះដោយទុកតែកូនណាដែលថ្លោសល្អ ហើយដកស្មៅ ដើម្បីឱ្យវាឆាប់លូតលាស់។ ចំពោះការស្រោចទឹកវិញ គឺធ្វើឡើង ១ ឬ២ដងក្នុង១ថ្ងៃ។ បន្ទាប់ពីកូនត្រប់ដុះបាន២អាទិត្យ យើងត្រូវប្រើជីលាមកសត្វពុកផុយបំប៉នបន្ថែម។ នៅពេលដែលត្រប់ចាប់ចេញផ្កា និងក្ដិប យើងត្រូវថែទាំយ៉ាងហ្មត់ចត់ដោយស្រោចទឹកឱ្យបានគ្រប់គ្រាន់ និងដកស្មៅដើម្បីបំផុសដី។

**៤. ការប្រមូលផល**

ក្រោយពីដាំបានរយៈពេល ៣ខែ យើងអាចប្រមូលផលដោយប្រើកាំបិតកាត់ទងត្រប់ ព្រោះទងវារាងស្វិតបន្តិច។ យើងគួរទុកពូជមួយចំនួនដោយជ្រើសរើសផ្លែថ្លោសល្អ គ្មានជំងឺ ឬសត្វល្អិតបំផ្លាញ។

សរុបមកបច្ចេកទេសសំខាន់ក្នុងការដាំត្រប់ឱ្យបានផលច្រើននោះ គឺជាការភ្ជួររាស់ កប់បញ្ចូលលាមកសត្វក្នុងដី និងហាលដីឱ្យស្ងួតល្អ។ ត្រាំគ្រាប់ពូជក្នុងទឹកក្ដៅឧណ្ហៗ ហើយផ្អាប់ទុក ២យប់ ៣ថ្ងៃ ដើម្បីដាស់ដំណេកគ្រាប់ឱ្យបានឆាប់ដុះ។ ប្រើជីធម្មជាតិ ( កំប៉ុស្ដ) ទ្រាប់បាតដាក់ក្នុងរណ្ដៅពេលដាំ និងប្រើជីបំប៉នពេលជិតចេញផ្កា។ ថែទាំស្រោចទឹកឱ្យជាប់ពេលលជិតចេញផ្កាដើម្បីឱ្យត្រប់ចេញផ្កាបានច្រើន និងកាន់ផ្លែ។ ជ្រើសរើសផ្លែថ្លោសៗល្អ និងមិនមានការបំផ្លាញដើម្បីទុកធ្វើពូជពេលដាំលើកក្រោយ។

## បរិស្ថាន

### ជីវៈចម្រុះកម្រថ្មី

យោងតាមការស្រាវជ្រាវមួយ ដែលធ្វើឡើង រួមគ្នារវាងអង្គការមូលនិធិសត្វព្រៃពិភពលោក (W-WF) រដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើរបស់



Photo : DR

ក្រសួងកសិកម្មកាលពីឆ្នាំ២០០៦ និង២០០៧ គេបានរកឃើញនូវជីវៈចម្រុះដ៏កម្របំផុតរស់នៅតាមដងទន្លេមេគង្គកម្ពុជាប្រវែង៥៥គីឡូម៉ែត្រ ចន្លោះរវាងទីរួមខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ បើតាមសេចក្ដីប្រកាសព័ត៌មានមួយរបស់ WWF ចេញផ្សាយកាលពីដើមឆ្នាំ២០០៩ បង្ហាញថា ការសិក្សាស្រាវជ្រាវទាំងនេះបានជម្រុញ ឱ្យមានការរកឃើញដ៏ឱ្យភ្ញាក់ផ្អើល ជាពិសេស ការរកឃើញសត្វ និងរុក្ខជាតិប្រភេទថ្មីដែលអ្នកវិទ្យាសាស្ត្រ ពុំធ្លាប់ស្គាល់ពីមុនដល់ទៅចំនួន ២៤ប្រភេទ នៅលើទឹកដីប្រទេសកម្ពុជា និងពូជសត្វចំនួន ៣៩ប្រភេទទៀតដែលជិតផុតពូជនៅលើពិភពលោក។ ពូជរុក្ខជាតិថ្មីដែលត្រូវបានរកឃើញនោះ គឺជារុក្ខជាតិ Amorphophallus ដែលជារុក្ខជាតិស្ថិតនៅក្នុងអំបូរត្រាវ។ ក្រៅពីនេះ គេក៏បានរកឃើញរុក្ខជាតិ ត្រី និងល្ងនកម្រនៅប្រទេសកម្ពុជា ជាច្រើនទៀតផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ គេរកឃើញសត្វស្លាបពីរប្រភេទគឺត្រយ៉ងចង្កំកស និងសត្វខ្មុតដីមេគង្គ ថែមទាំងហ្វូងសត្វត្រចៀកកាំក្នុងវ័យបន្តពូជដ៏ច្រើនសន្ធឹកសន្ធាប់នៃតំបន់អាស៊ីអាគ្នេយ៍ និងសម្បុកសត្វ កន្ធាយក្បាលកង្កែប ដែលជាសត្វជិតផុតពូជផងដែរ។ ការរកឃើញដ៏សំខាន់មួយទៀតនៅទីនោះគឺព្រៃលិចទឹកកម្ពស់ខ្ពស់ៗ ផ្លូវទឹក ប្រជុំកោះ ដែលជាផ្នែកដ៏សំខាន់នៃដងទន្លេមេគង្គ និងជាកន្លែងមិនទាន់មានតាំងលំនៅដ្ឋាននៅឡើយ។

www.ka-set.info





# ទស្សនវិស័យរបស់ PSE គឺដើម្បីភាពញញឹមនៃកុមារ

**ជាត សំភី**



Photos : DR

សិស្សផ្នែកសណ្ឋាគារ PSE ចុះអនុវត្តការងារផ្ទាល់ នៅ Grand Hotel ខេត្តសៀមរាប ឆ្នាំ២០០៨

ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលគួបផ្សំនិងទស្សនវិស័យខ្លួនគឺ "ដើម្បីភាពញញឹមនៃកុមារ" អង្គការដើម្បីភាពញញឹមនៃកុមារ ឬប៉េអេសអឺ (PSE) ក៏បានរៀបចំនូវកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាឯកទេសដល់សិស្សក្រីក្រដើម្បីឱ្យគេមានលទ្ធភាពរស់នៅសមរម្យក្នុងសង្គម។

បើតាមប្រសាសន៍របស់លោកឡា វិបុល ជានាយកគ្រប់គ្រងរបស់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈនៃអង្គការដើម្បីភាពញញឹមនៃកុមារ (PSE ប៉េ-អេសអឺ) បានប្រាប់ថា មកដល់ពេលនេះយើងមានបណ្ដុះបណ្ដាលជំនាញចំនួន១៩ ដូចជា ជំនាញគ្រប់គ្រងសណ្ឋាគារ ឬភោជនីយដ្ឋាន ចុងភៅ សេវាកម្មសណ្ឋាគារភោជនីយដ្ឋាន ការធ្វើនំ ការរៀបចំបន្ទប់ ការងារការិយាល័យ ជំនាញគណនេយ្យ ជំនាញរដ្ឋ-បាល ជំនួយការនាយក គ្រប់គ្រងការលក់ ឬទីផ្សារ ជំនាញកាត់សក់ ជំនាញថែទាំរថយន្ត ជំនាញខាងតទុយោទឹក ជំនាញលាបពណ៌ ជំនាញរៀបចំដាក់ការ៉ូ ជំនាញអគ្គិសនី ជំនាញរៀបចំសួនច្បារ និងការថែទាំក្មេង-ល-។កូនសិស្សដែលកំពុងរៀនជំនាញទាំងនេះ សព្វថ្ងៃមានប្រមាណ៧០០នាក់។ ដោយឡែកសិស្សដែលរៀនផ្នែកសណ្ឋាគារ និងភោជនីយដ្ឋានមានច្រើនជាងគេ គឺជាង២០០នាក់។ ចំណែកខាងពាណិជ្ជកម្ម ក៏មានជិត២០០នាក់ដែរ។ ជំនាញទាំងនេះសិក្សាពី១ឆ្នាំ ៣ខែ ទៅ៣ឆ្នាំ កន្លះ។ ចំណែកឯលក្ខខណ្ឌជ្រើសរើស គឺសាលាទទួលសិស្សពីសាលាចំណេះទូទៅ PSE និងធ្វើការសម្ភាសន៍។

លោកឡា វិបុល ក៏អះអាងដោយក្ដីរីករាយថា សព្វថ្ងៃ យើងមានមោទនភាពដោយមានការគាំទ្រអំពីម្ចាស់សហគ្រាស ឬអាជីវកម្មផ្សេងៗ ពិសេសម្ចាស់សណ្ឋាគារ ដែលតែងតែវាយតម្លៃអំពីគុណភាពនៃសិស្សរបស់សាលាយើង ដែលមានសមត្ថភាព និងគុណភាពពិតប្រាកដចំពោះជំនាញ ដែលពួកគេបានសិក្សា។ ជាក់ស្ដែង គឺសិស្សទាំង៧ ជំនាន់នៃសាលាសណ្ឋាគារនិងភោជនីយដ្ឋាន ដែលបានបញ្ចប់នូវវគ្គសិក្សា គឺទទួលការងារបាន ១០០%។

អង្គការ PSE គឺមានទីតាំងស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។ អង្គការនេះ ក៏ចាប់ដំណើរការចាប់ពីឆ្នាំ១៩៩៥មក ដោយស្ថានិកគូស្វាមីភរិយាជនជាតិបារាំងពីររូប គឺ Marie-France និង Christian Despallières។

# លោកឡា វិបុល : "ខ្ញុំចាប់អារម្មណ៍រឿងមនុស្សធម៌"

ជាមួយកុំព្យូទ័រលែបថបនៅពីមុខ លោកឡា វិបុល ហាក់ដូចជាផ្ចង់អារម្មណ៍យ៉ាងខ្លាំងទៅលើការងារនៅក្នុងការិយាល័យមួយ ដ៏ថ្លង់អ៊ូអែ ដោយសម្លេងសិស្សម៉ោងចេញលេង។ លោកជានាយកគ្រប់គ្រងមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅក្នុងអង្គការដើម្បីភាពញញឹមនៃកុមារ។ អតីតនិស្សិតខាងគ្រប់គ្រងសហគ្រាស នៅឯសកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងសេដ្ឋកិច្ច រូបនេះក៏ធ្លាប់ជាអតីតបុគ្គលិកក្រុមហ៊ុនជំនួញមួយ បន្ទាប់ពីលោកបានបញ្ចប់ការសិក្សានៅឆ្នាំ២០០១ មកផងដែរ។

តែចាប់ពីឆ្នាំពី២០០៣ មកដោយសារចង់ផ្លាស់ប្ដូរស្ថានភាព លោកក៏បានងាកមកធ្វើការនៅអង្គការ PSE ដោយដំបូងត្រឹមជាគ្រូបង្រៀន។ ស្ថិតក្នុងវ័យ២៨ឆ្នាំ បុរសមានគ្រួសារ និងបុត្រពីរនាក់រូបនេះ ក៏មានប្រសាសន៍ថា: "ខ្ញុំចង់ដូរការងារ។ នៅឯក្រុមហ៊ុន គឺគេធ្វើយ៉ាងណាឱ្យតែបានចំណេញ"។ លោកនិយាយដោយសង្កត់សម្លេងថា: "តែខ្ញុំមានចំណាប់អារម្មណ៍រឿងមនុស្សធម៌ជាង"។ លោកបន្តទៀត



Photos : P. Samphy

ថា នៅអង្គការជាកន្លែងមនុស្សធម៌ ពិសេសវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលយើងអាចជួយកុមារក្រីក្រ ឱ្យមានភាពញញឹមឡើងវិញ ពីព្រោះថា ថ្ងៃអនាគត ពួកគេអាចមានការងារចិញ្ចឹមជីវិតដោយមិនលំបាកវេទនាទៀតឡើយ។

ដូច្នេះក្នុងនាមជាអ្នកដែលដើរមុន មួយជំហានក្នុងការប្រឡូកក្នុងវិស័យការងារ លោកគ្រាន់តែមានអនុសាសន៍តិចតួចដល់យុវជនថា ជីវិតរបស់គេ ជាផ្លែផ្កា។ ដូច្នេះនៅក្នុងយុវវ័យដែលគេហៅថា វ័យឈាមរាវ ពួកគេត្រូវចេះតម្រង់ទិសដៅជីវិតដោយមានការប្រឹក្សា ជាមួយឪពុកម្ដាយ ឬអ្នកជិតដិតក៏បាន។ ម្យ៉ាងយុវជន ក៏ត្រូវចេះគ្រប់គ្រងអារម្មណ៍របស់ខ្លួនដើម្បីឱ្យលទ្ធផលនៃការសិក្សាបានល្អផង។

April-2009.qxd 3/25/2009 4:07 PM Page 8



## ប្រមុខរដ្ឋាភិបាល : "ថ្ងៃ ១៨ មីនា ១៩៧០ ជាឫសគល់នៃសង្គ្រាមស៊ីវិលនៅកម្ពុជា

សម្ដេចហ៊ុន សែន ប្រមុខរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា ថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ គឺជាឫសគល់នៃសង្គ្រាមស៊ីវិលក្នុងប្រទេស ។ សម្ដេចបានបញ្ជាក់នៅក្នុងសន្និបាតក្រសួងអប់រំ កាលពីរសៀលថ្ងៃទី១៨ ខែមីនា នៅវិទ្យាស្ថានជាតិអប់រំ នៅរាជធានីភ្នំពេញថា : "ប្រសិនជាមិនមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់សម្ដេចឪទេនោះ ស្រុកខ្មែរមិនដឹងជាមានការរីកចម្រើនប៉ុនណាទេ" ។ សម្ដេចបានបញ្ជាក់សាឡើងវិញថា បើសិនមិនមានរដ្ឋប្រហារទេនោះ ក្នុងរយៈពេល ៣៩ឆ្នាំ កន្លងមកនេះ កម្ពុជាមិនដឹងជារីកចម្រើនដល់ណានោះទេ ។ សូមបញ្ជាក់ផងដែរថា ថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាថ្ងៃ ដែលសេនាប្រមុខលន់ ណល់ បានដឹកនាំរដ្ឋប្រហារមួយទម្លាក់សម្ដេចនរោត្តម សីហនុ ចេញពីតំណែងជាព្រះប្រមុខរដ្ឋ ហើយប្រកាសប្រទេសកម្ពុជាថា គឺជា ប្រទេសដែលប្រកាន់របបសាធារណៈរដ្ឋ ។ បន្ទាប់ពីនោះមក សង្គ្រាមស៊ីវិលមួយ បានផ្ទុះឡើងរហូតដល់ចុងឆ្នាំ១៩៩៨ ទើបរលត់ ។

## ជប៉ុនផ្ដល់ជំនួយ និងកម្ចីជាង ៤០លានដុល្លាដល់កម្ពុជា

ទឹកប្រាក់ចំនួនប្រមាណជាជាង ៤០ លានដុល្លារ បានត្រូវរដ្ឋាភិបាលប្រទេសជប៉ុន សម្រេចចិត្តផ្ដល់ឱ្យប្រទេសកម្ពុជាតាមរយៈ ជាប្រាក់កម្ចីដែលមានការប្រាក់ទាប និងជាជំនួយអត់សំណងសម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍ និងដោះមីននៅក្នុងប្រទេសកម្ពុជា ។ កិច្ចព្រមព្រៀងនេះបានត្រូវបានធ្វើការចុះហត្ថលេខាដោយលោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងការបរទេសជាមួយនិងលោកកាស៊ីហ៊ីរ៉ូ ស៊ីណូណោរ៉ា ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា នៅក្រោមអធិបតីភាពរបស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០០៩កន្លងទៅ ។ នៅក្នុងចំណោមនោះទឹកប្រាក់ចំនួន ៣៥ ១៣០ ០០០ ដុល្លារ គឺជាប្រាក់កម្ចីសម្បទានសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅជាយក្រុងភ្នំពេញ និងទឹកប្រាក់ចំនួន ៥ ៤៨០ ០០០លានដុល្លារ ទៀត គឺជាគម្រោងជំនួយឥតសំណងសម្រាប់ផ្គត់ផ្គង់ជាសម្ភារៈដល់សកម្មភាពបោសសំអាតមីននៅប្រទេសកម្ពុជា ។

## គណបក្សប្រឆាំងយល់ព្រមធ្វើការជាមួយនិងគណបក្សកាន់អំណាច

សមាជិកគណបក្សសមរង្ស៊ី ពីររូបបានយល់ព្រមធ្វើការ ជាមួយនឹងសមាជិកគណបក្សកាន់អំណាចនៅក្នុងគណៈកម្មាធិការមួយដែលឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ។ លោក សុន ឆ័យ ដែលជាសមាជិកសភាគណបក្ស សមរង្ស៊ី បានមានប្រសាសន៍ប្រាប់ឱ្យដឹងកាលពីថ្ងៃ១៧ ខែមីនា ថា រូបលោក និងលោកគង់ គាំ ដែលជាសមាជិកព្រឹទ្ធសភា និងជាអនុប្រធានគណបក្សសមរង្ស៊ី បានសម្រេចចិត្តចូលរួមធ្វើការជាមួយនិងសមាជិកគណបក្សប្រជាជនកម្ពុជានៅក្នុងគណៈកម្មាធិការសម្រាប់កម្មវិធីដែលត្រូវបានឧបត្ថម្ភដល់ស្ថាប័នសភារបស់កម្ពុជាហើយ ។ លោកសុន ឆ័យបញ្ជាក់ទៀតដែរថា : "ពីមុនយើងធ្លាប់តែប្រឆាំងដោយមិនដែលបានចូលរួមសិក្ខាសាលាដែលរៀបចំឡើងដោយគណបក្សប្រជាជនទេ ប៉ុន្តែនៅពេលនេះដោយសារគណបក្សសមរង្ស៊ីក្លាយជាសមាជិកនៃគណៈកម្មាធិការនោះដែរ យើងនឹងចូលរួមធ្វើការ" ។

**ខាន់ ភីរម្យ**

## សម្ដេចប៉ាបទៅបំពេញទស្សនកិច្ចនៅអាហ្វ្រិក


Photo : DR

សម្ដេចប៉ាបបេណេឌីចទី ១៦ បានចាកចេញពីបុរីវ៉ាទីកង់ កាលពីថ្ងៃ១៧ មីនា ទៅបំពេញទស្សនកិច្ច តាមបណ្ដាប្រទេសនៅទ្វីបអាហ្វ្រិកជាលើកទី១ ចាប់តាំងពីព្រះអង្គបាន ត្រូវគេជ្រើសរើសជាសម្ដេចប៉ាបកាលពីឆ្នាំ២០០៥ កន្លងទៅ ។ តាមទីភ្នាក់ងារព័ត៌មានអេភី ក៏បានឱ្យដឹងថា ព្រះអង្គបានយាងទៅដល់ប្រទេសកាមឺរូនហើយនៅក្នុងដំណើរបំពេញទស្សនកិច្ចរយៈពេល ៦ថ្ងៃរបស់ព្រះអង្គទៅកាន់ទ្វីបអាហ្វ្រិកលើកនេះ ព្រះអង្គបានយាងទៅកាន់ប្រទេសអង់ហ្គោឡាផងដែរ ។ នៅក្នុងដំណើរបំពេញទស្សនកិច្ចនៅក្នុងប្រទេសអាហ្វ្រិកទាំងពីរនេះ ព្រះអង្គបានស្វែងយល់ពីការពិតជាក់ស្ដែងទាំងឡាយ ដែលកំពុងតែកើតមាននៅក្នុងតំបន់ដូចជា បញ្ហានៃភាពក្រីក្រ អំពើពុករលួយ ជម្លោះ និងជំងឺផ្សេងៗជាដើម ។

អាហ្វ្រិកជាទ្វីប ដែលត្រូវគេបានចាត់ទុកថា មានប្រជាពលរដ្ឋដែលមានជំនឿលើកាតូលិកច្រើនជាងគេបំផុតមួយ ក្នុងចំណោមទ្វីបនានា ដែលមានអ្នកជឿលើកាតូលិកទាំងអស់នៅលើពិភពលោក ។ គេបានធ្វើការប៉ាន់ប្រមាណថា នៅក្នុងចំណោមប្រជាពលរដ្ឋទាំងអស់នៅអាហ្វ្រិក គឺមានប្រជាពលរដ្ឋប្រមាណជា ១៥៨លាននាក់ មានជំនឿលើកាតូលិក ។

## សហរដ្ឋអាម៉េរិកបង្ហោះយានអវកាសដោយទទួលបានជោគជ័យ

បន្ទាប់ពីពន្យាពេលនៃការបង្ហោះ រយៈពេលមួយខែ ដោយសារតែបញ្ហាបច្ចេកទេសនោះ កាលពីថ្ងៃទី១៥ ខែមីនា អាម៉េរិកបានបង្ហោះយានឌីស្កូវើរីរបស់គេដោយជោគជ័យ និងបាននាំអវកាសយានិកចំនួន៧នាក់ ចាកចេញពីផែនដី ជាមួយឧបករណ៍ជាច្រើនសម្រាប់បំពេញការស្រាវជ្រាវរបស់ពួកគេ ។

តាមកាសែតញូវយ៉កថែម សម្ភារៈដែលយាននេះបានដឹកជញ្ជូនទៅនោះ មានប្រព័ន្ធការពារពន្លឺព្រះអាទិត្យ ម៉ាស៊ីនចម្រោះទឹកនោមឱ្យក្លាយជាទឹកផឹក និងសម្ភារៈមួយចំនួនទៀតដើម្បីពង្រីកស្ថានីយអវកាសអន្តរជាតិ ។ នៅមុនថ្ងៃទី២៥ ខែមីនា យានឌីស្កូវើរី នឹងត្រូវចូលទៅចតនៅស្ថានីយអវកាសដោយសារតែស្ថានីយនេះត្រូវពង្រីកបំបែកបន្ថែម ដើម្បីសង់បន្ទប់ថ្មីមួយទៀត សម្រាប់បម្រើដល់កិច្ចស្រាវជ្រាវរបស់ពួកគេនៅលើពិភពអវកាស ។

អវកាសយានិកដែលចាកចេញពីផែនដីកាលពីថ្ងៃទី១៥ ខែមីនា គឺសុទ្ធសឹងតែជាជនជាតិអាម៉េរិក តែមានម្នាក់ជាជនជាតិជប៉ុន ។

**ខាន់ ភីរម្យ**





# ១៣ឆ្នាំ សម្រាប់បេសកកម្មជាគ្រីស្តទូតនៅកម្ពុជា

**ខាន់ ភីរម្យ**

*ថ្ងៃទី២២ មីនា ឆ្នាំ២០០៩ លោកបូជាចារ្យអូមែរ ហ្ស៊ីរ៉ាល់ដូ នៃក្រុមយ៉ារ៉ូម៉ាល់ ត្រូវចាកចេញពីប្រទេសកម្ពុជា បន្ទាប់ពីបានមកជួយដល់ប្រជាពលរដ្ឋក្រីក្រ និងព្រះសហគមន៍កាតូលិកតាំងតែពីឆ្នាំ ១៩៩៥មក។ ខាងក្រោមនេះគឺជាបទសម្ភាសន៍រវាងអ្នកនាំសារ និងរូបលោក។*

**អ្នកនាំសារ : រយៈពេលជាង ១៣ឆ្នាំនេះ តើលោកបូជាចារ្យបានជួយអ្វីខ្លះដល់ប្រជាពលរដ្ឋខ្មែរ និងព្រះសហគមន៍កាតូលិកនៅកម្ពុជា ?**

**លោកអូមែរ** : ខ្ញុំមកដល់កម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ ១៩៩៥ ។ ពេលមកដល់ ខ្ញុំត្រូវរៀនភាសាខ្មែរ ១ឆ្នាំ បន្ទាប់មកទៅជួយព្រះសហគមន៍កាតូលិកនៅខេត្តកំពង់ធំ ។ ខ្ញុំបានចំណាយពេល១៤ខែ នៅឯកំពង់ធំ ព្រមនិងជួយបង្កើតទេវវិទ្យាល័យនៅភ្នំពេញ ។ ពីឆ្នាំ១៩៩៨-២០០១ ខ្ញុំបង្រៀនទស្សនវិជ្ជានៅទេវវិទ្យាល័យ ។ ស្របគ្នានេះដែរ ខ្ញុំបានផ្ដួចផ្ដើមគំនិតជួយព្រះសហគមន៍បឹងទំពុនដែលនាពេលនោះមានគ្រីស្តបរិស័ទក្មេងៗ តិចតួចប៉ុណ្ណោះ ។ តែពេលនេះ បឹងទំពុន ក៏ក្លាយជាព្រះសហគមន៍កាតូលិកមួយធំ និងមានសកម្មភាពជាច្រើន ។ ចាប់ពីឆ្នាំ២០០០ ខ្ញុំទៅទទួលខុសត្រូវព្រះសហគមន៍កំពង់ចាម ហើយនិងជួយព្រះសហគមន៍កាតូលិកនៅឯអ្នកលឿង ។ យើងមានសកម្មភាពច្រើន ដូចជា ក្រុមអប់រំជំនឿក្រុមគ្រីស្តបរិស័ទ ជួយដល់អ្នកក្រីក្រគណៈកម្មការសង្គហៈ និងជួយនិស្សិតក្រីក្រឱ្យបន្តការសិក្សា ជាដើម ។ក្នុងឆ្នាំ២០០៣ ខ្ញុំក៏បង្កើតការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ដែលវាជាកម្មវិធីព័ត៌មានមួយក្នុងនាមព្រះសហគមន៍ភូមិភាគទាំងបី ។


Photo : P. Samphy

លោកបូជាចារ្យអូមែរ ហ្ស៊ីរ៉ាល់ដូ ផ្ដល់បទឱ្យអ្នកនាំសារអំពីបទពិសោធន៍ជាគ្រីស្តទូត មុននឹងលោកចាកចេញពីកម្ពុជា

**អ្នកនាំសារ : តើលោកជួបការលំបាកអ្វីខ្លះក្នុងភារកិច្ចជាគ្រីស្តទូត និងការងារមនុស្សធម៌នៅកម្ពុជា ?**

**លោកអូមែរ** : ការលំបាកបំផុតគឺរៀនភាសាខ្មែរ តែការងារផ្សេងៗគ្មានការលំបាកទេ ។ បងប្អូនខ្មែរ គួរឱ្យរាប់អានណាស់ ។ ពេលខ្ញុំរៀនភាសាពីដំបូង គេសើច ។ កាលមួយនោះខ្ញុំចង់និយាយថា អស់កម្លាំងស្រាប់ តែខ្ញុំនិយាយថាអស់កម្លោះ ( សើច! ) ។

**អ្នកនាំសារ : តើលោកបូជាចារ្យទទួលបទពិសោធន៍អ្វីខ្លះនៅក្នុងរយៈពេលជាង ១៣ឆ្នាំនេះ ?**

**លោកអូមែរ** : ខ្ញុំមាននូវអំណរសប្បាយដែលឃើញវប្បធម៌ជនជាតិខ្មែរ បានបន្សល់ទុកពីបុរាណពិតៗ ខណៈដែលវប្បធម៌ដើម នៅអាម៉េរិកឡាទីនរបស់ខ្ញុំ បាត់អស់រលីង ។ ខ្ញុំក៏មានអំណរសប្បាយដោយស្គាល់បងប្អូនខ្មែរ ដែលជាជនជាតិមួយចេះតស៊ូ និងស្វែងរកសន្តិភាពខ្លួនឯង ។ នេះជាបទពិសោធន៍ល្អមួយសម្រាប់ប្រជាជនកូឡុំប៊ី ដែលកំពុងតែរងទុក្ខលំបាកដោយសង្គ្រាមឧទ្ទាម ។

**អ្នកនាំសារ : លោកបូជាចារ្យបានអះអាងថា លោកចូលចិត្តប្រជាជនកម្ពុជា ហើយចង់បន្តជួយកម្ពុជា តើហេតុអ្វីបានជាលោកត្រូវចាកចេញពីកម្ពុជា ?**

**លោកអូមែរ** : ខ្ញុំពុំចង់ចាកចេញនោះទេ ។ តែដើម្បីពាក្យសច្ចៈដែលខ្ញុំបានសន្យាជាមួយនឹងក្រុម ខ្ញុំត្រូវតែយល់ព្រមចាកចេញមួយរយៈដើម្បីជួយកិច្ចការក្រុម ។ ខ្ញុំអាចនឹងត្រឡប់មកវិញ ៦ឆ្នាំក្រោយ ។

## ជីវប្រវត្តិនៃលោក អូមែរ ហ្ស៊ីរ៉ាល់ដូ

លោកអូមែរ ហ្ស៊ីរ៉ាល់ដូ មីរ៉េស ជាបូជាចារ្យមួយរូបនៃក្រុមយ៉ារ៉ូម៉ាល់ ដែលមានសមាជិកជាង ២០០នាក់។ លោកកើតនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៥៥នៅប្រទេសកូឡុំប៊ី ពីត្រកូលគ្រួសារសាមញ្ញ និងមានបងប្អូន ១២នាក់។ នៅក្នុងចំណោមបងប្អូនទាំងអស់គឺមានតែលោកម្នាក់គត់ដែលបានក្លាយជាបូជាចារ្យដោយសារតែលោកចាប់អារម្មណ៍នឹងបេសកកម្មរបស់ព្រះសហគមន៍តាំងពីលោកមានអាយុ ១៥ឆ្នាំមកម្ល៉េះ។ លោកបានក្លាយជាសមាជិកក្រុមយុវជនជួយអ្នកដទៃដ៏សកម្មមួយរូបនៅលើទឹកដីកំណើតរបស់លោក។ នៅអាយុ ២០ឆ្នាំ លោកបានសម្រេចចិត្តចូលសិក្សានៅទេវវិទ្យាល័យ ហើយត្រូវបានតែងតាំងជាបូជាចារ្យនៅអាយុ ២៨ឆ្នាំ។ លោកធ្លាប់មានបទពិសោធន៍រស់នៅជាមួយនិងជនជាតិកូឡុំប៊ីស្បែកខ្មៅ។ កាលពីឆ្នាំ១៩៩៥ លោកក៏បានសម្រេចចិត្តមកបំពេញភារៈកិច្ចជាគ្រីស្តទូតមួយរូបនៅប្រទេសកម្ពុជា។


Photo : S. Philong

លោកបូជាចារ្យអូមែរ ហ្ស៊ីរ៉ាល់ ថតរូបអនុស្សាវរីយ៍ជាមួយកុមារនៅព្រះសហគមន៍អ្នកលឿង។ ក្នុងរយៈពេល ១៣ឆ្នាំ នៃបេសកកម្មជាគ្រីស្តទូតនៅប្រទេសកម្ពុជា លោកបូជាចារ្យតែងតែជួយជនក្រីក្រមិនឈប់ឈរជាមួយនិងអំណរសប្បាយ។

April-2009.qxd 3/25/2009 4:07 PM Page 10



# សាលាក្តីខ្មែរក្រហមដំណើរការរហូត តែពលរដ្ឋ ខ្លះមិនបានដឹង

**ខាន់ ភីរម្យ**

រហូតមកដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា ឬហៅថាតុលាការខ្មែរក្រហមដែលបានដំណើរការរហូតដល់មានការចាប់ឃុំឃាំងមេដឹកនាំខ្មែរក្រហមសំខាន់ៗ ៥រូប បានប្រឈមមុខនឹងវិបត្តិថវិកា ពោលគឺមានកង្វះខាតប្រាក់ខែ បើកជូនបុគ្គលិក។ ប៉ុន្តែទោះជាយ៉ាងណា បញ្ហានេះត្រូវបានដោះស្រាយមួយរយៈក្រោយពេលប្រទេសជប៉ុនប្រកាសផ្តល់ជំនួយចំនួន ២០០០០០ដុល្លារបន្ថែមទៀត។

លោកគង់ ស្រ៊ីម ប្រធានតុលាការកំពូលនៃសាលាក្តីខ្មែរក្រហម មានប្រសាសន៍ កាលពីដើម ខែមីនាកន្លងទៅនេះថា វាគឺជារឿងគួរឱ្យសោកស្តាយមួយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខាងភាគីកម្ពុជាអស់ថវិកាដើម្បីបើកប្រាក់ខែជូនបុគ្គលិកតុលាការទាំងស្រុង។

ប៉ុន្តែដោយសារតែបញ្ហានេះដដែល ស្ថានទូតជប៉ុនប្រចាំនៅប្រទេសកម្ពុជាបានប្រកាសជួយ ក្រោយពីរដ្ឋាភិបាលកម្ពុជាប្រកាសស្វែងរកនូវប្រាក់ជំនួយសម្រាប់សាលាក្តីនេះឱ្យដំណើរការបានបន្តទៅមុខទៀត នាខណៈពេលដែលសាលាដំបូងសាលាក្តីខ្មែរក្រហម បានកំណត់ពេលនាំយកសំណុំរឿងក្តីរបស់ប្រធានមន្ទីរឃុំឃាំងទួលស្លែងឈ្មោះកាំង ហ្គិចអ៊ាវ ហៅឌុច យកទៅជំនុំជម្រះរកការពិត នៅក្នុងថ្ងៃទី ៣០ ខែមីនាកន្លងទៅនេះ។

ព័ត៌មានស្តីអំពីការខ្វះខាតថវិការបស់សាលាក្តីខ្មែរក្រហមនេះ បានធ្វើឱ្យមជ្ឈដ្ឋានសាធារណៈជន ជាពិសេសអ្នកដែលជាជនរងគ្រោះពីរបបនេះ មាននូវការអល់អែកនៅក្នុងការបង្ហាញអំពីសេចក្តីសង្ឃឹមរបស់ពួកគេ សម្រាប់ការស្វែងរកពន្លឺយុត្តិធម៌ពីជនទាំង៥នាក់នេះដែលជាមេដឹកនាំជាន់ខ្ពស់នេះ។

ប៉ុន្តែសម្រាប់ប្រជាជនមួយចំនួនវិញ គាត់ហាក់ដូចជាពុំរវីរវល់នឹងសាលាក្តីនេះឡើយ ហើយគាត់បាននិយាយហាក់ដូចជាមិនដឹងថា នៅពេលនេះ កម្ពុជាកំពុងតែរៀបចំឱ្យមានសាលាក្តីកាត់ទោសពួកមេដឹកនាំខ្មែរក្រហមទាំង៥រូបនេះទៀតផង បើទោះបីជាពួកគេគឺជាជនដែលរងគ្រោះផ្ទាល់នៅក្នុងរបបខ្មែរក្រហម ហើយមានសាច់ញាតិបានបាត់បង់ជីវិតនៅក្នុងរបបនេះក៏ដោយចុះ។



Photo : S. Philong

## ជនសង្ស័យពីបទប្រល័យពូជសាសន៍

**មេដឹកនាំខ្មែរក្រហមដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចចិត្តចាប់ឃុំឃាំងដើម្បីធ្វើការជំនុំជម្រះទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងរបបខ្មែរពីឆ្នាំ១៩៧៥ ដល់១៩៧៩នោះ មានចំនួន៥រូប។ ទី១ លោកខៀវ សំផន ប្រមុខរដ្ឋរបស់របបខ្មែរក្រហមត្រូវ ត្រូវចាប់ខ្លួននៅថ្ងៃទី១៣ វិច្ឆិកា ឆ្នាំ២០០៧។ ទី២ លោកនួន ជា ប្រធានសភា ត្រូវចាប់ខ្លួននៅថ្ងៃទី១៩ កញ្ញា ឆ្នាំ២០០៧។ ទី៣ លោកអៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងភរិយារបស់គាត់ គឺលោកស្រីអៀង ធារិទ្ធិ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរបស់របបខ្មែរក្រហម ត្រូវចាប់ខ្លួននៅថ្ងៃទី១២ វិច្ឆិកា ឆ្នាំ២០០៧ និងសម្រាប់លោកកាំង ហ្គិចអ៊ាវ ហៅឌុចអតីត ប្រធានមន្ទីរឃុំឃាំង និងធ្វើទារុណកម្មទួលស្លែង ត្រូវចាប់ខ្លួនមុនគេ ក្រោយពេលដែលកាសែតបរទេសមួយសម្ភាសន៍លោកកាលពីឆ្នាំ១៩៩៧។**

លោកយាយថុត អាយុ៦៧ឆ្នាំ ប្រជាពលរដ្ឋនៅក្នុងភូមិវត្តចាស់ ស្រុកមុខកំពូល នាខេត្តកណ្តាល បានមានប្រសាសន៍ថា គាត់បានក្លាយទៅជាស្ត្រីមេម៉ាយដល់សព្វថ្ងៃ ដោយសារតែរបបខ្មែរក្រហមនេះឯង ប៉ុន្តែលោកយាយ ហាក់ដូចជា មិនបានដឹងអ្វីសោះពីដំណើរការសាលាក្តីខ្មែរក្រហម សូម្បីតែការចាប់ខ្លួនមេដឹកនាំរបស់របបនេះ ក៏គាត់មិនបានដឹងដែរ។

លោកយាយដែលជាអ្នកលក់ផ្លែត្រសក់ស្រូវទុំនៅផ្លូវជាតិលេខ ៦អា រូបនេះ ក៏បន្តថា: "ចៅអើយ! យាយមិនដឹងទេ។ យាយចាំបានតែថា តាគាត់ឈឺស្លាប់ពេលបែកអំពេញ(ភ្នំពេញ)បាន១ឆ្នាំ។ កាលណោះបើមានថ្នាំដូចឥឡូវគាត់ពុំស្លាប់ទេ។ សម័យអាពត(ប៉ុលពត) យើងរស់នៅ វារវេទនាណាស់"។ លោកយាយក៏បញ្ជាក់ទៀតថា: "អើយខ្ជិល! រវល់ខ្ញុំចាស់ហើយ គេធ្វើអ្វី ធ្វើទៅ"។

លោកតាបេ ទែន អាយុ ៦៣ឆ្នាំ បានធ្លាប់ជាអតីតទាហានលន់ ណល់។ គាត់រងរបួសត្រង់ស្មា និងសព្វថ្ងៃនេះ គាត់រស់ជាមួយនិងអំបែងគ្រាប់នៅក្នុងដៃ និងកំភួនជើងរយៈពេលជាង ៣០ឆ្នាំ។ គាត់ជាប្រជាពលរដ្ឋ ក្នុងភូមិកកោះ ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ លោកតា មានប្រសាសន៍ថា មកដល់ពេលនេះ គាត់ជាប្រជាពលរដ្ឋម្នាក់នៅក្នុងចំណោមប្រជាពលរដ្ឋ ដែលមិនបានទទួលព័ត៌មានពីសាលាក្តីខ្មែរក្រហមសោះដែរដោយសារតែបញ្ហាជីវភាព។ លោកតាបានឱ្យដឹងថា នរណាក៏ឈឺចាប់ដែរ ឱ្យតែអ្នកដែលធ្លាប់រស់ក្នុងសម័យខ្មែរក្រហមជាពិសេសឱ្យគេរំលឹកដល់។ ប៉ុន្តែមកដល់ពេលនេះ អ្នកភូមិភាគច្រើនហាក់ដូចជាលែងនឹកនាហើយ។ ពួកគេភាគច្រើនគិតតែរឿងរកស៊ីប៉ុណ្ណោះ។ លោកតាបញ្ជាក់ថា: "កាលពីដើម ខ្ញុំដើរទៅណាមកណាស្រួល។ ខ្ញុំមានវិទ្យុមួយគ្រាន់ស្តាប់ ហើយឧស្សាហ៍ជួបគ្នា ទើបព័ត៌មានចេះតែមាន ប៉ុន្តែពេលនេះ ខ្លួនវាក៏ចាស់ ទៅណាមកណាមិនកើត ហើយអាវិទ្យុក៏ខូចទៀតបានជាមិនសូវដឹង។ ហើយបើនិយាយអំពីកូន ពួកវាគិតតែពីរឿងរកស៊ីចិញ្ចឹមកូនប៉ុណ្ណោះ"។

លោកតាម្នាក់ទៀតឈ្មោះអ៊ឹម ចេវ បច្ចុប្បន្ន គឺជាសមាជិកគណៈកម្មាធិការអាចារ្យវត្តប្រាសាទជ័យមង្គល នៅក្នុងភូមិកកោះ ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាមដែរនោះបានឱ្យដឹងថា គាត់ដឹងដែរពីរឿងសាលាក្តីខ្មែរក្រហមខ្លះៗ តាមរយៈការស្តាប់វិទ្យុ។ ប៉ុន្តែវាមិនជាញឹកញាប់ទេ។ លោកតាបន្ថែមថា: "ថ្ងៃខ្លះក៏ស្តាប់ទៅ។ ឯថ្ងៃខ្លះក៏ខានទៅ តែព័ត៌មាន វាមិនច្បាស់ គ្រាន់តែដឹងថា ឥឡូវនេះគេចាប់ខៀវ សំផន ហើយ"។

ជាមួយបញ្ហានេះ មន្ត្រីជាន់ខ្ពស់របស់អង្គការ ក្រៅរដ្ឋាភិបាលមួយ បានអះអាងថា ជនរងគ្រោះដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហមទាំងអស់ នរណាក៏នៅចងចាំអំពីទុក្ខវេទនា និងការឈឺចាប់ដែលកើតមានឡើងចំពោះពួកគេនៅក្នុងរបបនេះដែរ។ ប៉ុន្តែដោយសារកត្តាជីវភាព និងសេដ្ឋកិច្ច នៅពេលសព្វថ្ងៃនេះ ស្របជាមួយនិងពេលវេលា ដែលចេះអូសបន្លាយយូរមក ជនរងគ្រោះមួយចំនួនអាចនឹងមានការរសាយចិត្តខ្លះ និងប្រសិនមិនមានអ្នកណារំឭកអំពីព្រឹត្តិការណ៍នោះឡើងវិញទេនោះ។

កញ្ញាសេង ធារី នាយិកានៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម មានប្រសាសន៍ថា: "ដោយសារភាពក្រីក្រ ពួកគាត់អាចព្រួយពីការរកលុយ ឱ្យកូនទៅរៀន។ វាសំខាន់ជាងព្រួយអំពីសាលាក្តីខ្មែរក្រហម។ ប៉ុន្តែបើយើងរំលឹកគាត់នោះ គាត់ច្បាស់ជាចងចាំពីទុក្ខវេទនា និងចង់ឃើញយុត្តិធម៌មិនខាន"។

ជាមួយនឹងបញ្ហានេះមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានស្វែងរកថវិកា ដោយជោគជ័យនៅក្នុងមួយឆ្នាំប្រមាណជា ២០ម៉ឺនដុល្លារ ដើម្បីជួយជំរុញប្រជាពលរដ្ឋកម្ពុជា ឱ្យមានការចងចាំឡើងវិញតាមរយៈគម្រោងផ្សេងៗ ដូចជារៀបចំនូវវេទិកាសាធារណៈ ការបោះពុម្ពឯកសារដើម្បីជំរុញការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាននិងកម្មវិធីជួយផ្នែកផ្លូវចិត្តជាដើម។ ជាមួយគម្រោងកម្មវិធីទាំងនេះ កញ្ញាសេង ធារី ក៏បានអះអាង ដោយជំនឿយ៉ាងមុតមាំថា រហូតមកដល់សព្វថ្ងៃនេះ នៅក្នុងចំណោមប្រជាពលរដ្ឋចំនួន ១៤លាននាក់ យ៉ាងហោចណាស់ ក៏មានប្រជាពលរដ្ឋ៦០% ដែលបានទទួលព័ត៌មានអំពីសាលាក្តីខ្មែរក្រហម។ កញ្ញាបញ្ជាក់ថា: "ពេលចាប់ផ្តើមដំបូងប្រជាពលរដ្ឋខ្លះគាត់មិនហ៊ាននិយាយឡើយ ពីការឈឺចាប់របស់ពួកគាត់។ ប៉ុន្តែដល់ពេលគាត់ ឮអ្នកដ៏ទៃនិយាយនៅក្នុងវេទិកាផ្សេងៗ។ គាត់បានចាប់ផ្តើមបង្ហាញពីការឈឺចាប់គាត់ភ្លាមៗ"។

បើតាមការអះអាងរបស់កញ្ញា ដល់ពេលនេះបញ្ហាសង្គមមួយចំនួនដែលបានកើតមានឡើងនៅកម្ពុជាដូចជា បញ្ហាអំពើហិង្សានៅក្នុងគ្រួសារ វាអាចមានឫសគល់ចេញមកពីការឈឺចាប់របស់ពួកគាត់ដែលកើតមានឡើងនៅក្នុងសម័យខ្មែរក្រហម។

កញ្ញាបានឱ្យដឹងថា ដោយសារតែគាត់មានការឈឺចាប់ខ្លាំង ហើយអត់ហ៊ានបញ្ចេញ។ ដល់ពេលយូរទៅ គាត់អាចមានជំងឺផ្លូវចិត្តរហូតដល់ក្លាយខ្លួនទៅជាអ្នកញៀនស្រាជាដើម និងត្រឡប់មកជះកំហឹងដាក់គ្រួសារ។ អ៊ីចឹងហើយបានយើងចង់ឱ្យពួកគាត់ហ៊ាននិយាយ និងហ៊ានបំភ្លឺពីរឿងរ៉ាវដែលពួកគាត់បានឃើញនៅក្នុងរបបខ្មែរក្រហមនេះ។

លោកជុំ ម៉ាញ អតីតអ្នកទោសគុកទួលស្លែង សព្វថ្ងៃនេះ អាយុ ៧៨ឆ្នាំ បានឱ្យដឹងថា គាត់ចង់បាននូវយុត្តិធម៌មែនទែន ពីពួកមេដឹកនាំខ្មែរក្រហមដែលបានចោទប្រកាន់គាត់ថា ជាភ្នាក់ងារកាហ្សេបេ ឬស៊ីអាយអេ (KGB ដែលគេស្គាល់ថា វាជាភ្នាក់ងារសម្ងាត់របស់អតីតសភាពសូវៀត ឬCIA ដែលជាទីភ្នាក់ងារស៊ើបការសម្ងាត់របស់អាមេរិក)។

លោកតាបញ្ជាក់ថា: "ខ្ញុំចង់បានយុត្តិធម៌ ចំពោះអ្វីដែលគេបានឆក់ខ្សែភ្លើង ដកក្រចក និងធ្វើទារុណកម្មខ្ញុំសព្វយ៉ាងដោយមិនមានកំហុស។ ខ្ញុំតឹងទ្រូងណាស់ពេលដែលនឹកឃើញគេធ្វើទារុណកម្មខ្ញុំ"។

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការដែលរួមគ្នាបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម។ តុលាការនេះបានត្រូវបង្កើតឡើង ហើយដំណើរការនៅក្នុងឆ្នាំ២០០៧ ក្រោយពេលដែលរដ្ឋសភាកម្ពុជាបានអនុម័តច្បាប់មួយនៅក្នុងឆ្នាំ២០០១ ដើម្បីនាំខ្លួនអ្នកទទួលខុសត្រូវដល់ការស្លាប់មនុស្សចំនួនប្រមាណជា ២ លាននាក់ ទៅកាត់ទោស និងក្រោយពេលដែលអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយគ្នាកាលពីឆ្នាំ២០០៣។ តុលាការនេះជាតុលាការឯករាជ្យ មិនចំណុះឱ្យរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិទេ។ ប៉ុន្តែការចូលរួមពីសហគមន៍អន្តរជាតិធ្វើឱ្យការអនុវត្តមានស្តង់ដារអន្តរជាតិ។ តុលាការនេះនឹងផ្តល់ជាគំរូតួនាទីថ្មីមួយសម្រាប់ដំណើរការកាត់ក្តីនៅប្រទេសកម្ពុជា។**

April-2009.qxd 3/25/2009 4:07 PM Page 12



# អគារភូមិភាគកាតូលិកភ្នំពេញត្រូវសម្ពោធឱ្យប្រើប្រាស់

**កែវ កញ្ញា**

អគារការិយាល័យនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មាននាមថា សម្ដេចប៉ាប បេណេឌិតូទី ១៦ ក៏ត្រូវបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ នៅក្រោមអធិបតីភាពលោកអគ្គអភិបាលដ៏ឧត្ដុង្គឧត្ដមសាលវ៉ាទ័រ ពេណ្ណាគីអូ ជាអគ្គរាជទូតនៃសន្ដអាសនៈសម្ដេចប៉ាប ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកអេមីល ដេតម្ប ជាអភិបាល ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ព្រមទាំងមានការចូលរួមពីគ្រីស្ដបរិស័ទជាង ២០០នាក់ទៀត ។ កម្មវិធីនេះធ្វើឡើងកាលពីថ្ងៃទី១០ មីនាកន្លងទៅ នៅអាសយដ្ឋានលេខ៥៧ ផ្លូវ១០១ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

នាឱកាសនោះ លោកសាលវ៉ាទ័រ ពេណ្ណាគីអូ ក៏បានថ្លែងថា: "ថ្ងៃនេះ យើងមានអំណរសប្បាយដោយសារបងប្អូនមាននូវអគារថ្មី ដែលជាកន្លែងដែលបងប្អូនអាចជួបជុំគ្នា និងធ្វើការរួមគ្នា ឱ្យប្រសើរឡើងដោយប្រើកម្លាំងកាយ និងគំនិតប្រាជ្ញា។ សូមព្រះជាម្ចាស់ណែនាំ និងប្រទានពរដល់បងប្អូន មានចិត្តក្លាហានក្នុងការប្រកាសដំណឹងល្អដូចសន្តប៉ូល" ។

លោកបូជាចារ្យ អូលីវីយេ តំណាងពេញសិទ្ធិលោកអភិបាលភូមិភាគភ្នំពេញមានប្រសាសន៍ថា: "ជាង ១ឆ្នាំហើយ ដែលយើងមានគណៈកម្មាការផ្សេងៗ ដូចជាចំណេះទូទៅ អប់រំជំនឿយុវជនយុវនារី និងសុខភាព។ អ៊ីចឹងប្រសិនយើងមានការិយាល័យនៃគណៈកម្មាធិការនីមួយៗ ដូចជាការផ្ដល់កម្លាំងចិត្តដល់យើងដែរ ពីព្រោះគណៈកម្មាធិការទាំងអស់នៃព្រះសហគមន៍នៅកន្លែងនេះ ទី១ មានទំនាក់ទំនង ទី២ស្គាល់គ្នា និងទី៣ ជួយឱ្យយើងបម្រើព្រះសហគមន៍យ៉ាងសកម្ម" ។

មុនពេលមានអគារនេះ កិច្ចទំនាក់ទំនងរវាងគណៈកម្មាធិការមួយ ជាមួយគណៈកម្មាធិការមួយទៀត មានការលំបាក ព្រោះគ្មានព័ត៌មានលំអិត ។

លោកបូជាចារ្យអូលីវីយេ ក៏គូសបញ្ជាក់ថា អ្វីដែលសំខាន់នោះ ពុំមែនអគារទេ គឺមនុស្សអាចជួបជុំគ្នា



Photo : S. Philong

**លោកអគ្គអភិបាលសាលវ៉ាទ័រ ពេណ្ណាគីអូ លោកអភិបាលអេមីល ដេតម្ប និងលោកឪពុកអូលីវីយេ ផ្ទិតបាស្លេ រួមគ្នាសម្ពោធអគារភូមិភាគកាតូលិកភ្នំពេញ**

និងមានសកម្មភាពដើម្បីជួយ ឱ្យគ្រីស្ដបរិស័ទតាមព្រះសហគមន៍នីមួយៗ ។

អគារភូមិភាគនេះ មានគណៈកម្មាធិការចំនួន ៤: គណៈកម្មាធិការសកម្មភាពយុវជន-នារី និងកុមារ គណៈកម្មាធិការអប់រំជំនឿ គណៈកម្មាធិការសង្គហៈ និងគណៈកម្មាធិការអប់រំចំណេះដឹងទូទៅ ។

## រៀបចំកម្មវិធីសម្រាប់យុវជនដែលចង់ជួយ

ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ស្វែងរកយុវជន យុវនារីកាតូលិក ដែលមានបំណងជួយបម្រើព្រះសហគមន៍រយៈពេលពីបីខែរហូតដល់មួយឆ្នាំ ដើម្បីទទួលបានបទពិសោធន៍ការងារមនុស្សធម៌ ។ យុវជនអាចធ្វើការងារស្ម័គ្រចិត្តក្រោយបញ្ចប់ការសិក្សាថ្នាក់ទី១២ ឬបញ្ចប់ថ្នាក់ឧត្ដមសិក្សា ។

បេសសកម្មរបស់ព្រះសហគមន៍នៃភូមិភាគកំពង់ចាមមានចំនួន ៧កន្លែង និងកម្មវិធីដូចជាអប់រំជំនឿអប់រំកូនក្មេងនិងកុមារ បណ្ណាល័យ កម្មវិធីមត្តេយ្យសាលា បង្រៀនភាសា មុខវិជ្ជាគណិត កុំព្យូទ័រ កសិកម្ម ឬជំនួយការតាមមណ្ឌលសិក្សានានាក្នុងព្រះសហគមន៍ បច្ចេកទេសអគ្គិសនី និងគ្រឿងម៉ាស៊ីន សរសេរព័ត៌មាន គ្រូពេទ្យ ឬសន្តិករ (អ្នកបង្កើតសន្តិភាព) ជាដើម ។ ទូរស័ព្ទ : ០១២ ៤៧៦ ១៨៩ ឬ០១២ ៩៤៩ ១០០ ។ **កំពង់ចាម**

## CSC ផ្លាស់ប្ដូរដើម្បីការប្រកួតប្រជែងថ្មី

**ការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រីស្ដដល់ប្រជាជនជិតឆ្ងាយ ការសហការណ៍ជាមួយព្រះសហគមន៍កាតូលិកដោយការអនុគ្រោះ និងយោគយល់គ្នា គំនិតស្ថាបនា និងការចូលរួមសកម្មភាពព្រះសហគមន៍ដើម្បីផ្ដល់សង្ឃឹមដល់ប្រជាជន តាមរយៈបច្ចេកវិទ្យាទំនើបខាងប្រព័ន្ធផ្សព្វផ្សាយ ទាំងអស់នេះគឺជាបេសកកម្មចម្បងរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា។**

**ស្ថិតក្រោមការដឹកនាំរបស់លោកអូមែរ ហ្សឺរ៉ាល់ដូ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក បានបង្កើតនូវកម្មវិធីជាច្រើនដើម្បីបញ្ជ្រាបទស្សនៈ និងគុណតម្លៃរបស់ព្រះសហគមន៍កាតូលិកនៅក្នុងសង្គម។**

**បច្ចុប្បន្ននេះ ការិយាល័យផ្សព្វផ្សាយព្រះសហគមន៍កាតូលិកដឹកនាំ និងគ្រប់គ្រងដោយគ្រីស្ដបរិស័ទខ្មែរម្នាក់ ដែលបានអភិវឌ្ឍន៍សមត្ថភាព និងទេពកោសល្យខ្លួនក្នុងភាពជាអ្នកដឹកនាំក្នុងព្រះសហគមន៍។**

**ផ្អែកតាមសេចក្ដីប្រកាសព័ត៌មាន របស់លោកអភិបាលអេមីល ដេតម្ប អភិបាលភូមិភាគភ្នំពេញ បញ្ជាក់ថា លោកលី សុវណ្ណា គឺជានាយកថ្មីនៅក្នុងការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍។ កញ្ញាកែវ កញ្ញា ជាអនុប្រធាន និងលោកបូជាចារ្យប៉ូល រឿង ឆត្រឆ័យ សាសនទូតថៃជាអ្នកសម្របសម្រួល។**

**លោកអភិបាលអេមីល ដេតម្ប បានមានប្រសាសន៍ថា ការិយាល័យផ្សព្វផ្សាយព័ត៌មាន ត្រូវមានសកម្មភាពតទៅមុខដោយឈរលើមូលដ្ឋានសំខាន់ៗ ៣ គឺការអប់រំបណ្ដុះបណ្ដាល សហប្រតិបត្តិការ និងការសន្ទនា។ ការអប់រំបណ្ដុះបណ្ដាល គឺផ្ដើមចេញពីបុគ្គលិកនៅក្នុងការិយាល័យផ្សព្វផ្សាយ និងមនុស្សពីខាងក្រៅ មានន័យថា បុគ្គលិកត្រូវពង្រឹងសម្ថភាព និងមានឆន្ទៈខ្ពស់នៅក្នុងការងារសម្រាប់ព្រះសហគមន៍។ សហប្រតិបត្តិការគឺទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយលោកអភិបាលបើកចិត្តគំនិតទទួលយកគំនិតផ្ដួចផ្ដើមផ្សេងៗរបស់គ្រីស្ដបរិស័ទ និងសមាគមន៍កាតូលិកផ្សេងៗទៀត ព្រមទាំងទាក់ទងឱ្យមានប្រសិទ្ធភាពជាមួយប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។ ចំណែកការសន្ទនាមានសារៈសំខាន់សម្រាប់ការងារដើម្បីបង្កើតនូវជំនឿទុកចិត្ត និងការរីកចម្រើនរបស់ប្រព័ន្ធផ្សព្វផ្សាយកាតូលិក។**

**ហ្វិដេស**





# សប្ដាហ៍ពិសិដ្ឋ សម្រាប់គ្រីស្ដបរិស័ទ

**ខាន់ ភីរម្យ**

លោកអេមីល ដេតម្ប ជាអភិបាលព្រះសហគមន៍កាតូលិកប្រចាំភូមិភាគភ្នំពេញ មានប្រសាសន៍ថា គ្រីស្ដបរិស័ទកម្ពុជាទាំងអស់ កំពុងត្រៀមខ្លួនរៀបចំពិធីបុណ្យប្រពៃណីដ៏សំខាន់មួយរបស់ខ្លួននាដើមខែមេសា ខាងមុខនេះ គឺបុណ្យចម្លង ។

ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ចែងថា ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ ។ ប៉ុន្តែសាសនាផ្សេងៗ ក៏ត្រូវបានគោរពផងដែរ ។ លោកអភិបាលអេមីល បញ្ជាក់ថា នៅកម្ពុជា អ្នកកាន់សាសនាកាតូលិកមានប្រមាណ ១៨០០០នាក់តែប៉ុណ្ណោះ ។ តែយើងមានសិទ្ធិសេរីភាពដ៏បរិបូរដើម្បីរៀបចំនូវពិធីផ្សេងៗ តាមជំនឿរបស់យើង ។ ហើយចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១២ ខែមេសានេះ យើងនឹងរៀបចំពិធីបុណ្យដ៏សំខាន់មួយដែលហៅថា "សប្ដាហ៍ពិសិដ្ឋ និងបុណ្យចម្លង" ។

លោកអភិបាលបន្ថែមថា: "សប្ដាហ៍ពិសិដ្ឋ គឺជាពិធីបុណ្យដែលរំឭកដល់ព្រះយេស៊ូដែលបានជួយរំដោះបាបទាំងអស់ដែលបង្កឡើងដោយមនុស្ស" ។

"សប្ដាហ៍ពិសិដ្ឋ"នេះ ព្រះសហគមន៍កាតូលិករៀបចំឡើង គឺដើម្បីរំឭកដល់សកម្មភាពចុងក្រោយរបស់ព្រះយេស៊ូនៅលើលោក នៅមុនពេលដែលព្រះអង្គយាងទៅស្ថានបរមសុខ ។ នៅថ្ងៃអាទិត្យ មានពិធីបុណ្យហែស្លឹក រំឭកដល់ព្រះយេស៊ូ យាងចូលក្រុងយេរូសាឡឹម ។ ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ មានពិធីដើម្បីរំឭកថ្ងៃដែលព្រះយេស៊ូ ធ្វើពិធីជប់លៀងនាគ្រាចុងក្រោយជាមួយនឹងក្រុមសាវ័ក គឺមុនពេលដែលព្រះអង្គត្រូវគេចាប់ខ្លួនយកទៅកាត់ទោស ។ នាពិធីជប់លៀងនេះ ព្រះអង្គក៏យកនំប៉័ង មកកាច់ប្រទានឱ្យក្រុមសាវ័ក តំណាងឱ្យព្រះកាយរបស់ព្រះអង្គ និងស្រាទំពាំងបាយជូតំណាងឱ្យព្រះលោហិតរបស់ព្រះអង្គ ។ នៅថ្ងៃសុក្រពិសិដ្ឋ មានពិធីបុណ្យព្រះយេស៊ូរងទុក្ខលំបាកដើម្បីរំឭកនៅពេលដែលព្រះអង្គត្រូវបានគេកាត់ទោសយកទៅឆ្កាងរហូតដល់អស់ព្រះជន្ម ។ ចំណែក នៅរាត្រី ថ្ងៃសៅរ៍ពិសិដ្ឋ និងព្រលឹមថ្ងៃអាទិត្យ គ្រីស្ដបរិស័ទរៀបពិធីបុណ្យមួយ ទៀត គឺបុណ្យលើកតម្កើងព្រះជាម្ចាស់ ប្រោសព្រះយេស៊ូឱ្យមានព្រះជន្មថ្មីដ៏រុងរឿង ឬហៅ "បុណ្យចម្លង" ។

## ព្រះសហគមន៍កាតូលិក

# ភូមិភាគទាំងបី

ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានចាប់កំណើតអស់រយៈពេលជាង ៤៥០ឆ្នាំ មកហើយ ។

នៅឆ្នាំ១៥៥៥ លោកហ្គាស្ប៉ា ដាគ្រូស បព្វជិតព័រទុយហ្គាល់ នាំដំណឹងអំពីគ្រីស្ដសាសនាមកប្រទេសកម្ពុជា ។ លោកស្ថិតនៅព្រះរាជវាំងក្រុងលង្វែក ។

នៅឆ្នាំ១៥៧៤ លោកសីលវែស្ត្រដាសេវេដូ ជាបព្វជិតព័រទុយហ្គាល់ មករស់នៅក្នុងប្រទេសកម្ពុជា ។ លោកនិយាយខ្មែរ កសាងព្រះវិហារមុនគេ ហើយបកប្រែសៀវភៅមួយជាភាសាខ្មែរទៀតផង ។

ក្នុងអំឡុងឆ្នាំ១៧៦៨ ដល់ឆ្នាំ១៧៧៧ លោកឡឺវ៉ាវ៉ាសើរ ជាបូជាចារ្យជាតិបារាំងនិពន្ធសៀវភៅខាងគ្រីស្ដសាសនាជាភាសាខ្មែរ និងអប់រំនិស្សិត ឱ្យទៅជាបូជាចារ្យ ហើយក៏បានបង្កើតនូវគ្រួសារបព្វជិតាកាតូលិកមួយក្រុម ។

នៅដើមសតវត្សរ៍ ទី១៩ ព្រះរាជាណាចក្រកម្ពុជាជួបប្រទះតែភ្លើងសង្គ្រាម ។ ព្រះសហគមន៍ត្រូវរងគ្រោះដោយសារភ្លើងសង្គ្រាមនោះផងដែរ ។ នាឆ្នាំ ១៨៥០ សន្ដអាសនៈក៏បានតែងតាំងលោកយ៉ូហានក្លូដ មីស្ស ឱ្យធ្វើជាអភិបាលភូមិភាគភ្នំពេញ ។

នៅឆ្នាំ១៨៦៦ ព្រះបាទនរោត្ដម សុំឱ្យគ្រីស្ដបរិស័ទខ្មែរចាកចេញពីតំបន់ពញាឮ មកតាំងទីលំនៅ នៅរាជធានីភ្នំពេញវិញ ។ ព្រះរាជាចែកដីឱ្យគ្រីស្ដបរិស័ទសាងព្រះវិហារនៅព្រែកហ្លួង ។

លុះមកដល់សម័យអាណានិគមនិយមបារាំង មានគ្រីស្ដបរិស័ទវៀតណាមជាច្រើនបានរស់នៅលើទឹកដីកម្ពុជា ។ នាឆ្នាំ១៩៥២ វត្តអារាមបព្វជិតកាតូលិកកសាងឡើងនៅក្រុងកែបខេត្តកំពត ។

ថ្ងៃទី៧ វិច្ឆិកា ឆ្នាំ១៩៥៧ លោកស៊ីមន ឈឹម យិន ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅវិសាលវិហារថ្មីភ្នំពេញ ។ លោកជាបូជាចារ្យខ្មែរដំបូង ។

នៅឆ្នាំ១៩៧០ ព្រះសហគមន៍ចាត់ចែង ឱ្យមានជាគណៈកម្មការសង្គហៈ ដើម្បីជួយសង្គ្រោះ ដល់ជនរងគ្រោះ ដោយសារសង្គ្រាម ក្រោយមកបានក្លាយទៅជាអង្គការ "ការីតាកម្ពុជា" ។

ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ព្រះសហគមន៍កាតូលិកបានឆ្លងកាត់សម័យវិនាសកម្មខ្មែរក្រហម ។ នៅថ្ងៃទី៣ មេសា ឆ្នាំ១៩៩០ ព្រះសហគមន៍ទទួលច្បាប់អនុញ្ញាតពីរដ្ឋាភិបាលដើម្បីចាប់ផ្ដើមឡើងវិញ ។

**អ្នកនាំសារ**

**ថ្ងៃទី២៦ កញ្ញា ឆ្នាំ ១៩៦៨ សន្ដអាសនៈ ចែកព្រះសហគមន៍កាតូលិកនៅកម្ពុជា ជាបីភូមិភាគ គឺ ភូមិភាគភ្នំពេញ បាត់ដំបង និង កំពង់ចាម។**




Photo : DR

## សោកនាដកម្មខ្មែរ

នៅថ្ងៃទី១៤ មេសា ឆ្នាំ១៩៧៥ លោកយ៉ូសែប ឆ្មារ សាឡាស ទទួលអគ្គសញ្ញាតែងតាំងជាអភិបាលឧបត្ថម្ភករនៃព្រះសហគមន៍ភ្នំពេញ។ ប៉ុន្តែលោកយ៉ូសែប ឆ្មារ សាឡាស លោកប៉ូល ទេពអ៊ឹម សុត្ថា អស់លោកបូជាចារ្យ និងអស់បព្វជិតកាតូលិកខ្មែរ ព្រមទាំងគ្រីស្ដបរិស័ទមួយចំនួនធំបានបាត់បង់ជីវិតនៅក្នុងសម័យប្រល័យពូជសាសន៍ប៉ុលពត។ ចំណែកព្រះវិហារត្រូវគេបំផ្លាញខ្ទេចខ្ទីអស់គ្មានសល់។

April-2009.qxd 3/25/2009 4:07 PM Page 14



# សកម្មភាព នាថ្ងៃអាទិត្យ នៅសហគមន៍គងនយ

**លី សុវណ្ណា**

*សហគមន៍គងនយ ចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ ៩០ តែហាក់ដូចជា ជួបប្រទះនូវការលំបាកជាខ្លាំង ដែលត្រូវការយកចិត្តទុកដាក់ ។*



លោកបូជាចារ្យពន្យល់អត្ថបទគម្ពីរដំណឹងល្អថ្ងៃអាទិត្យ ក្នុងពេលរៀបចំពិធីបុណ្យអភិបូជាជាមួយគ្រីស្តបរិស័ទ



សាលាប្រជុំដ៏កំសត់នៃសហគមន៍គងនយ ដែលស្ថិតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ១៥គីឡូម៉ែត្រ ពីភ្នំពេញ។



គ្រីស្តបរិស័ទទទួលបដិសណ្ឋារកិច្ចលោកបូជាចារ្យហ្វ្រង់ស្វ័រ សាវីយ៉េ ពេលទៅដល់ ដោយក្តីអំណរសប្បាយរីករាយ



សកម្មភាពក្នុងពិធីអភិបូជា ដែលដឹកនាំលោកបូជាចារ្យ ជាមួយនិងការយកចិត្តទុកដាក់ត្រងត្រាប់ស្តាប់ពីគ្រីស្តបរិស័ទ



ការច្រៀងទំនុកលើកតម្កើងព្រះជាម្ចាស់ និងសកម្មភាពការអានអត្ថបទព្រះគម្ពីរនៅក្នុងពិធីអភិបូជារបស់គ្រីស្តបរិស័ទដែលពោរពេញដោយជំនឿ



លោកបូជាចារ្យក្នុងសកម្មភាពចែកនំបុ័ងដែលតំណាងឱ្យព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទដែលចូលរួមអភិបូជា





# ផ្លែផ្កាសម្រាប់ការផ្សព្វផ្សាយដំណឹងល្អរបស់សាសនទូត

**អេឡាន ឡូរ៉ែយែរ**

ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាជាគ្រាប់ពូជខ្ចី ។ គ្រីស្តបរិស័ទមាន០,១% នៃចំនួនប្រជាជន និងក៏ធ្លាប់បានទទួលរងនូវទុក្ខបុកម្នេញ នៅក្រោមរបបខ្មែរក្រហម ។ ប៉ុន្តែក្នុងរយៈពេល ៣០ឆ្នាំ ព្រះសហគមន៍កាតូលិក បានរីកចម្រើនលឿនជាង នៅក្នុងអំឡុងពាសតវត្សរ៍មុន ។ ក្នុងរយៈពេល ១៥ឆ្នាំកន្លងមកនេះ មាននូវយុវជនជាច្រើនដែលបានចូលជាគ្រីស្តបរិស័ទ ។ កាលពីថ្ងៃអាទិត្យទីមួយ ខែមីនាសម្រាប់តែព្រះសហគមន៍កាតូលិក ប្រចាំភូមិភាគភ្នំពេញ អ្នកត្រៀមជ្រមុជទឹកចំនួន ៧១នាក់ ក៏បានត្រូវត្រាស់ហៅដើម្បីទទួលពិធីជ្រមុជទឹក ដែលដឹកនាំដោយលោកអភិបាលអេមីល ដេតម្ប នាឱកាសរាត្រីថ្ងៃបុណ្យចម្លងខាងមុខនេះ ។

លោកអភិបាលក៏បានជួបសន្ទនាជាមួយអ្នកត្រៀមជ្រមុជទឹកដើម្បីបង្ហាញប្រាប់អំពីសារៈសំខាន់របស់ពួកគេ និងការផ្លាស់ប្តូរទៅរកភាពចម្រើន ខាងផ្លូវវិញ្ញាណ ។ "សព្វថ្ងៃនេះប្រជាជនខ្មែរគឺកាន់តែបើកចំហចំពោះការប្រកាសដំណឹងល្អ ។ អនាគតគ្រីស្តបរិស័ទបានមកពីសហគមន៍កាតូលិកផ្សេងៗគ្នានៃភូមិភាគ ។ "នៅមុនរបបខ្មែរក្រហម ខ្ញុំជាសាសនទូតនៅក្មេង និងមានការខ្នះខ្នែងមួយរូប" ។ លោកអភិបាលរំឭក ។ តែពេលនោះខ្ញុំបានទទួលអ្នកផ្លាស់ប្តូរសាសនាតែ ៣នាក់ ប៉ុណ្ណោះក្នុង រយៈ ពេល១១ឆ្នាំ..." ។ ប៉ុន្តែសង្គ្រាម គឺដូចជាធ្វើឱ្យចិត្តគំនិតបាក់បែក ។ តើព្រះពុទ្ធសាសនាគឺលែងជួយពួកគេឱ្យរស់នៅទៀតមែនទេ ?" លោកអភិបាលបានចោទសួរខ្លួនឯង ។ យើងត្រូវបានតម្រូវឱ្យទទួលស្គាល់ថាការដោះទុក្ខមិនអាចមកពីកន្លែងផ្សេងក្រៅពីខ្លួនយើងនោះទេ ។ ព្រះយេស៊ូគ្រីស្ត ស្នើឱ្យមានការផ្លាស់ប្តូរទាំងស្រុងមួយ : "ចូរបើកចិត្តគំនិត ផ្តល់ឱ្យខ្លួនឯងផ្តល់ការជឿជាក់សម្រាប់ព្រះអង្គ ដើរតាមព្រះអង្គ និងស្រឡាញ់ព្រះអង្គ" ។

សំអាតនិយាយថា: "ខ្ញុំមានអាយុ ២៨ឆ្នាំ និងជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរនៅសាលាវិទ្យាល័យសន្តហ្វ្រង់ស្វ័រ នៅភូមិចំការទៀង" ។ សំអាតនឹងទទួលពិធីជ្រមុជទឹកនៅក្នុងភូមិរបស់លោកនារាត្រីថ្ងៃទី ១១ មេសាខាងមុខជាមួយ ១៦នាក់ផ្សេងទៀត ។ សំអាតទទួលស្គាល់ថា ពីដំបូងមានការស្អប់គ្រីស្តបរិស័ទ ដោយសារការមិនដឹង និងគំនិតដែលធ្លាប់មាន ។ ប៉ុន្តែនៅថ្ងៃមួយ នៅឆ្នាំ២០០៤ លោកបានរងរបួស ដោយសារគ្រោះថ្នាក់ចរាចរណ៍ម៉ូតូ ដ៏ធ្ងន់មួយ ។ លោករៀបរាប់ថា : "តែអ្នកជិតខាងរបស់ខ្ញុំដែលជាគ្រីស្តបរិស័ទបានជួយខ្ញុំដើម្បីព្យាបាល ។ ខ្ញុំមានការភ្ញាក់ផ្អើល ហើយសន្យាចំពោះខ្លួនឯងថានឹងស្វែងរកព្រះយេស៊ូគ្រីស្តបន្ទាប់ពីខ្ញុំបានជា ។ ខ្ញុំក៏មានការចាប់ចិត្តចំពោះទង្វើដែលព្រះយេស៊ូគ្រីស្តបានប្រទានជាជីវិតរបស់ទ្រង់ដើម្បីមកធ្វើព្យាបាល និងសង្គ្រោះមនុស្សលោក" ។

សូភី អាយុ ២១ ឆ្នាំ អ្នកត្រៀមជ្រមុជទឹកមួយរូបក៏ពន្យល់ថា : "ខ្ញុំជួបព្រះយេស៊ូតាមរយៈមិត្តភ័ក្ត ។ រឿងនេះធ្វើឱ្យជីវិតខ្ញុំផ្លាស់ប្តូរ ។ កាលពីមុន ខ្ញុំមានការអៀនប្រៀនខ្លាំងណាស់ ។ ឥឡូវខ្ញុំក៏រីករាយនឹងទំនាក់ទំនង និងជួយអ្នកដទៃ ។ សូភីដែលត្រូវបានព្រះសហគមន៍កាតូលិកជួយឱ្យបានរៀនសូត្រ មានប្រភពពីគ្រួសារក្រីក្រនៅខេត្តកំពត ។

Photos : L. Sovanna







April-2009.qxd 3/25/2009 4:08 PM Page 16



# ដួង សារ៉ង្ស : “ដំណឹងល្អ គឺព្រះជាម្ចាស់ស្រឡាញ់យើង...”

**លី សុវណ្ណា**



Photo : P. Samphy

លោកគ្រូដួង សារ៉ង្ស បុគ្គលិកបម្រើការងារនៅមជ្ឈមណ្ឌលវប្បធម៌កាតូលិក និងជាគ្រូអប់រំជំនឿសម្រាប់គ្រិស្តបរិស័ទ

លោកដួង សារ៉ង្ស មានប្រភពពីគ្រួសារមួយប្រកបដែលប្រកាន់ភាពសមហេតុផល និងការទទួលខុសត្រូវ ។ លោកទទួលនូវអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រិស្តបរិស័ទកាតូលិក កាលឆ្នាំ១៩៩៥ ។ លោកដួង សារ៉ង្ស ក៏ជាអតីតមន្ត្រីនៃកំពង់ផែស្វយ័តភ្នំពេញ ។ លោកទទួលនូវការអប់រំយ៉ាងហ្មត់ចត់ពីឪពុកម្ដាយក្នុងវ័យកុមារភាព ។ លោកក៏ធ្លាប់បួសជាសាមណេផងដែរនៅទសវត្សរ៍ទី៧០ ។ គឺដោយមានគ្រឹះនេះហើយ ទើបលោកខិតខំប្រព្រឹត្តខ្លួន យ៉ាងសមរម្យជាពុទ្ធសាសនិក និងយកចិត្តទុកដាក់ចំពោះទស្សនៈបុណ្យបាប និងកម្មផល ។ ក្រោយមកបទពិសោធន៍នៃជីវិតក្នុងវាលពិឃាត ធ្វើឱ្យលោកមានការរិះគិតកាន់តែជ្រៅឡើង ។ ដូច្នេះនៅក្នុងគ្រាលំបាកវេទនាសម័យនោះ នាំឱ្យលោកសួរខ្លួនឯងថា : “អ្វីជាការពិត?” ។ បុរសវ័យ៥៤ឆ្នាំរូបនេះ ក៏បន្តថា នៅពាក់ទសវត្សរ៍ទី៩០ លោកទទួលដំណឹងល្អអំពីព្រះយេស៊ូហើយសម្រេចចិត្តទទួលអគ្គសញ្ញាជ្រមុជទឹក ។

លោកដួង សារ៉ង្ស បញ្ជាក់ថា ទោះបីជាទទួលអគ្គ-សញ្ញាជ្រមុជទឹកហើយ រាល់ការបកស្រាយផ្សេងៗនៅតែមិនទាន់ឆ្លើយតបទៅចម្ងល់របស់លោកនៅឡើយ ។ លោកក៏ស្ម័គ្រចូលរួមបម្រើព្រះសហគមន៍ក្នុងគណៈកម្មការពិធីបុណ្យ ក្រោយមកចូលរួមក្នុងក្រុមអប់រំណែនាំជំនឿ ។ ដោយបទពិសោធន៍ថ្មីធ្វើក្នុងកិច្ចការព្រះសហគមន៍ ដែលតែងចែកយោបល់ និងកែតម្រូវគ្នាទៅវិញទៅ បណ្ដាឱ្យលោកមានចិត្តក្លាហានក្នុងការនិយាយបកស្រាយនូវអំពើអសកម្មមួយចំនួនបាននៅកន្លែងការងារនាពេលប្រជុំដោះ-ស្រាយបញ្ហា ។ លោកសង្កត់ធ្ងន់ ដោយការទុកចិត្តថា សេចក្ដីដែលលោកនិយាយ គឺនាំឱ្យសប្បាយចិត្តហើយប្រព្រឹត្តតាម ។ តាមរយៈហេតុការណ៍នេះ ក៏បណ្ដាលចិត្តលោក កាន់តែក្លាហានក្នុងការនិយាយដើម្បីជាប្រយោជន៍ដល់បងប្អូន ។

នៅឆ្នាំ២០០២ លោកលាឈប់ពីការងារចូលបម្រើកិច្ចរួមជាមួយ លោកបូជាចារ្យប៉ុងសូដ៏នៅមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា ។ កិច្ចការថ្មីនេះ ធ្វើឱ្យលោកមានការរីកចម្រើនថែមទៀតខាងជំនឿ និងបទពិសោធន៍ទាក់ទងទៅនឹងគម្ពីរព្រមទាំងរបៀបអប់រំជំនឿ ។ ក្នុងរយៈពេលជាង១០ឆ្នាំ ក្នុងមុខងារជាអ្នកណែនាំអប់រំជំនឿ លោកបង្ហាញពីវិធីខ្លះក្នុងការណែនាំយ៉ាងនេះថា យើងត្រូវយល់អំពីបងប្អូនត្រូវការអ្វី? ពេលខ្លះមកដើម្បីប្រយោជន៍ តែយើងត្រូវជួយឱ្យបងប្អូនយល់ និងបង្វែរបំណងរបស់គេ ។ បងប្អូនដែលមក គឺសុទ្ធតែខ្លាចបាប និងខិតខំសន្សំបុណ្យ ។ ដូច្នេះគឺត្រូវបើកចិត្តស្រឡាញ់គេឱ្យអស់ពីចិត្ត និងនាំដំណឹងល្អឱ្យគេយល់ថា គឺ “ព្រះជាម្ចាស់ស្រឡាញ់យើងទាំងអស់ រួចនាំឱ្យយើងមានសេរី-ភាពចេញពីភាពភ័យខ្លាចទាំងឡាយ” ។

## ប្រតិទិនអភិបូជា

- ភាសាខ្មែរ : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៩១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- ភាសាបារាំង : Saturday of 1st week and 3rd week at 5:30pm; Sunday of 2nd and 4th week at 11:00 am; At St. Joseph Church, #1788B, NR5, PP.
- ភាសាអង់គ្លេស : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).








Photo : S. Philong

# កតញ្ញូកូនខ្មែរ ពេលចូលឆ្នាំថ្មី

**ខាន់ ភីរម្យ**

លោកម្សៀច ប៉ុណ្ណ ជាទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរប្រចាំនៅវិទ្យាស្ថានពុទ្ធសាសនិកបណ្ឌិត មានប្រសាសន៍ថា ទម្លាប់យកជំនូនជូនមាតាបិតា ចាស់ព្រឹទ្ធាចារ្យ ជីដូនជីតា ដែលជាអ្នកមានគុណ នាវដូវចូលឆ្នាំ គឺជាទង្វើកតញ្ញូរបស់កុលបុត្រខ្មែរ ។

លោកម្សៀចប៉ុណ្ណ រៀបរាប់ទៀតថា ទម្លាប់នេះ មិនមែនជាប្រពៃណីដែលចាស់បុរាណខ្មែរ បានចងក្រងនៅក្នុងគម្ពីរ ឬក៏បានចែងក្នុងក្រឹត្យក្រមណាមួយ ក៏ទេ ។ តែជាទូទៅទម្លាប់នេះត្រូវបានកូនខ្មែរយើងអនុវត្ត ជាបន្តបន្ទាប់គ្រប់ជំនាន់ដើម្បីសម្ដែងនូវការដឹងគុណ ។ លោកបញ្ជាក់ថា : “ពិធីបុណ្យចូលឆ្នាំថ្មីជាប្រពៃណីដែលមានចែងច្បាស់លាស់ ។ ប៉ុន្តែការជូនជំនូនមិនមែនជាក្រឹត្យក្រម ។ តែជាសីលធម៌ដែលខ្មែរតែងប្រដៅកូនចៅតៗគ្នាគ្រប់ជំនាន់ឱ្យគោរពតាម” ។

លោកម្សៀច ប៉ុណ្ណ ពន្យល់ថា បុណ្យចូលឆ្នាំថ្មីគឺជាពិធីដែលមានអត្ថន័យមួយដ៏សំខាន់របស់ខ្មែរ ។ វាគឺជាពិធីមួយសម្រាប់បង្ហាញពីជោគជ័យរបស់ប្រជាជន បន្ទាប់ពីពួកគេបានពុះពាររាល់ឧបសគ្គ និងការលំបាកទាំងឡាយពេញ ១ឆ្នាំ ទម្រាំមកដល់ពេលចូលឆ្នាំនេះ ។ ហើយចូលឆ្នាំថ្មីនេះក៏ដូចជាបុណ្យខួបកំណើតសម្រាប់មនុស្សគ្រប់ៗគ្នាដែរ ។ ដូច្នេះការនាំយកជំនូនទៅជូនអ្នកមានគុណនៅក្នុងថ្ងៃនោះ គឺមានអត្ថន័យជ្រាលជ្រៅណាស់ ។ លោកក៏បន្តថា សម្រាប់អ្នកដែលបានខកខានមិនបានអនុវត្ត ក៏មិនមានដាក់ទោសពៃរ៍អ្វីដែរ ប៉ុន្តែជាទូទៅកូនខ្មែរតែងតែអនុវត្តគ្រប់ៗគ្នាជារៀងរាល់ឆ្នាំ ។

នេះគឺជាការពិត ពីព្រោះនៅរដូវបុណ្យទានធំៗ ជាពិសេសគឺចូលឆ្នាំថ្មី ឬបុណ្យភ្ជុំបិណ្ឌម្ដងៗ គេសង្កេតឃើញថា កុលបុត្រ កុល-ធីតាខ្មែរ តែងតែទៅជួបជុំគ្រួសាររបស់ពួកគេដោយនាំយកនូវលុយកាក់ ឬក៏របស់របរបន្តិចបន្តួចជាប់នឹងដៃទៅជូនឪពុកម្ដាយ ឬអ្នកមានគុណរបស់ពួកគេនៅទីកន្លែងដែលពួកគាត់កំពុងតែស្នាក់នៅ បើទោះបីជាពួកគេជាប់រវល់នូវការងារយ៉ាងណាក៏ដោយ ។ ពួកគេធ្វើដូច្នេះនៅមុនពេលទៅជួបជុំគ្នាធ្វើបុណ្យនៅតាមទីអារាម ។

លោកម្សៀច ប៉ុណ្ណ ពន្យល់បញ្ជាក់ថា: “ការយកជំនូនជូនអ្នកមានគុណ នៅពេលបុណ្យចូលឆ្នាំថ្មីនេះ មិនមានក្រឹត្យក្រមណាចែងច្បាស់ទេ។ ប៉ុន្តែសម្រាប់បុណ្យភ្ជុំបិណ្ឌ គេមានចែងច្បាស់លាស់ ជាពិសេស គឺចំពោះមាតា បិតា ឬក៏សាច់ញាតិ ដែលលោកបានចែកឋានទៅហើយ” ។ បើតាមប្រតិទិនឆ្នាំនេះ ប្រជាជនខ្មែរនឹងរៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំនេះពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសាខាងមុខនេះ ។

## អំណាន

### រឿងអង់ទីគ្អូន




រឿងនេះសរសេរឡើង ក្នុងទម្រង់ជាល្ខោនអូប៉េរ៉ា (opéra) ជាវិធី-សាស្ត្រដែលមជ្ឈដ្ឋានទូទៅ មិនសូវស្គាល់ ហើយអ្នកនិពន្ធខ្មែរសម័យថ្មីពុំសូវយកមកប្រើឡើយ ។

“អង់ទីគ្អូន” ជាស្នាដៃដ៏ឆ្នើមនៃអ្នកនិពន្ធក្រិច ដ៏ល្បីល្បាញម្នាក់ឈ្មោះ សូហ្វុក្ល ។ វាគឺជារឿងដែលគេយកមកសម្ដែងជាល្ខោន និងពុំចេះសាបរលាប នៅពាសពេញពិភពលោក ដោយសាររឿងនេះ នាំយើងឱ្យពិចារណាលើជីវិតមនុស្ស ការយល់ឃើញនូវមនោសញ្ចេតនារវាងបង និងប្អូន រវាងគូសង្សារដែលត្រូវគេបំបែកបំបាក់យ៉ាងព្រៃផ្សៃ-ល-។ ដោយសារចង់ឱ្យសពបងប្រុស មានផ្នូរតាមច្បាប់សាសនា អង់ទីគ្អូនមិនខ្លាចស្លាប់ ហ៊ានប្រឆាំងនឹងបំរាម របស់ស្ដេចក្រេអុងដែលបញ្ជាឱ្យគេទុកសាកសព នោះចោលដូចសត្វធាតុ ។ នាងក៏យកដីមករោយលើសពដើម្បីជានិមិត្តរូបនៃការបញ្ចុះសព ។ គ្រាន់តែប៉ុណ្ណេះ នាងត្រូវគេចាប់ចង រួចក៏បញ្ជូនទៅកប់ទាំងរស់...។

រឿងនេះបកប្រែជាភាសាខ្មែរដោយពុទ្រី ទត់ និងបោះពុម្ពនៅឆ្នាំ១៩៩៥ ដោយបណ្ណាគារអង្គរ ។

### អ្នកបដិវត្តក្លែងក្លាយ




“អ្នកបដិវត្តក្លែងក្លាយ” គឺជារឿងបែបប្រវត្តិសាស្ត្រ ដែលកើតមាននៅក្នុងសង្គមខ្មែរ សតវត្សរ៍ទី១៦ ក្នុងរជ្ជកាល ព្រះបាទស្រីសុគន្ធបទ គឺនៅពេលដែលប្រទេសខ្មែរ កំពុងជួបប្រទះភាពចលាចល និងជ្រួលច្របល់ ។

នេះគឺជារឿងដែលបានសរសេរឡើង ដោយប្រើឈ្មោះក្នុងប្រវត្តិសាស្ត្រ (តួអង្គ ឬតំបន់នានា) ឈ្មោះពិត ដែលអាចជំនួយដល់ការសិក្សាប្រវត្តិសាស្ត្រដល់អ្នកជំនាន់ក្រោយ ។ បន្ទាប់ពីបានគេចរួចខ្លួនពីការប៉ងធ្វើឃាតមកលើខ្លួនពីព្រះបាទស្រីសុគន្ធបទមក នាយកនក៏ដើរប្រមូលកៀងទ័ព និងអ្នកប្រាជ្ញចេះដឹងមួយចំនួនធំ ដើម្បីធ្វើការរំលំរាជបល្ល័ង្ក ។ ដោយសារតែមូលដ្ឋានគ្រឹះរឹងមាំដូចនេះ នាយកនក៏ទទួលជោគជ័យលើគ្រប់សមរភូមិ និងត្រូវបានប្រជាជន គោរពស្រលាញ់ពីគ្រប់ទិសតំបន់...។

និយាយរួមរឿងនេះ គឺនិយាយអំពីការប្រជែងគ្នារវាងអ្នកកាន់អំណាចខ្ពស់ៗ ដែលតែងមានមិនឈប់ឈរក្នុងសង្គមខ្មែរ ។ រឿងនេះនិពន្ធដោយសាំង ហ៊ែល និងត្រូវបានបោះពុម្ព នៅឆ្នាំ១៩៧២ ដោយបណ្ណាគារអង្គរ ។

**ហួត សុជាតា**

April-2009.qxd 3/25/2009 4:08 PM Page 18

## ប្រវត្តិសាស្ត្រ

# ជប៉ុន មហាអំណាចសូរិយារះនៅចុងបូព៌ា

**ជាត សំភី**

តាំងពី៩០០០ឆ្នាំ មុនគ្រីស្តសករាជ ប្រជាជនអាស៊ីខាងជើង បានមកតាំងទីលំនៅ នៅលើទឹកដីជប៉ុនដែលស្ថិតនៅខាងកើតប្រទេសចិន និងកូរ៉េ នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។

ប្រទេសជប៉ុន ឈានចូលសម័យប្រវត្តិសាស្ត្រដ៏ពិតប្រាកដ គឺចាប់ផ្តើមពីឆ្នាំ ៥៣៨ ជាមួយនិងការមកដល់នៃព្រះពុទ្ធសាសនាមកពីប្រទេសកូរ៉េ ។ ប្រវត្តិ-សាស្ត្រជប៉ុនបានវិវត្តន៍ជាមួយនិងការផ្លាស់ប្តូរកុលសម្ព័ន្ធដឹកនាំ និងសង្គ្រាមដើម្បីឯកភាពទឹកដី ។

នៅពាក់កណ្តាលសតវត្សរ៍ទី៧ ត្រកូល ណាកាតូមីបានបង្ក្រាបត្រកូលសូហ្គា និងបង្កើតនូវរបៀបគ្រប់គ្រងមួយដោយយកលំនាំទៅតាមរបៀបគ្រប់គ្រងរបស់ចិន ក្នុងរជ្ជកាលរាជវង្សថាង ។

ពីឆ្នាំ៨៥៨ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី១២ ត្រកូលហ្វូជីវ៉ារ៉ាកាន់កាប់អំណាច ។ លុះមកដល់ឆ្នាំ ១១៩២ មេកុលសម្ព័ន្ធត្រកូល មីណាម៉ូតូ ឬយ៉ូរីតូមី បានបង្ក្រាបកុលសម្ព័ន្ធអំណាចចាស់ ហើយត្រូវបានតែងតាំងជាអគ្គមហាសេនា (សូហ្គុន) ។ ចាប់តាំងពីពេលនោះ អំណាចមជ្ឈិមមានពីរ : មួយជារបស់ព្រះចៅអធិរាជ(តេនណូ) ។ មួយទៀតជាអំណាចរបស់សូហ្គុនដែលគ្រប់គ្រងរដ្ឋាភិបាល ។

ពីឆ្នាំ១២៧៤ ដល់ឆ្នាំ១២៨១ ការប៉ុនប៉ងចូលលុកលុយពីសំណាក់ជនជាតិម៉ុងហ្គោលចូលជប៉ុន ក៏ត្រូវបានវាយឱ្យបរាជ័យ ។ ចាប់ពីឆ្នាំ១៣៣៣-១៥៨២ (សម័យមុយរ៉ូម៉ាជី) សូហ្គុននៃត្រកូលអាស៊ីហ្គាកា បានមកតាំងរដ្ឋាភិបាលនៅទីក្រុងក្យូតូ ។ សង្គ្រាមស៊ីវិលបង្ហូរឈាមកើតមានឡើង គឺជាសង្គ្រាមរវាងអំណាចមជ្ឈិមទាំង២ និងសង្គ្រាមរវាងស្តេចត្រាញ់ទាំងឡាយ ហៅថា (ដេមយ៉ូ) ។

ពីឆ្នាំ១៥៨៥ដល់ឆ្នាំ១៥៩៨ តូយ៉ូតូមី អ៊ីដេយ៉ូស៊ី ជានាយករដ្ឋមន្ត្រីទី១របស់ព្រះចៅអធិរាជបានបង្រួបបង្រួមប្រទេសជប៉ុនឱ្យមានឯកភាពដោយបង្ក្រាបស្តេចត្រាញ់ទាំងឡាយដែលចង់ប្រកាសឯករាជ្យ ។ ក្រោយមរណភាពរបស់អ៊ីដេយ៉ូស៊ី ពីឆ្នាំ ១៦០៣-១៦១៦ លោកតូគូហ្គាវ៉ា អ៊ីយ៉េយ៉ាស៊ូ បានមកតាំងរាជធានីនៅអេដូ(តូក្យូបច្ចុប្បន្ន) និងបានប្រកាសខ្លួនជាសូហ្គុនបន្តនិងផ្តល់ឱ្យប្រទេសជប៉ុននូវស្ថាប័នរដ្ឋដែលមានស្ថិរភាពឡើងវិញ ។




Photos : DR

### ស្ថានភាពភូមិសាស្ត្ររបស់ប្រទេសជប៉ុន



ជប៉ុនជារដ្ឋមួយក្នុងមហាសមុទ្រប៉ាស៊ីហ្វិកដែលនៅលើកោះធំបួនសំខាន់ៗ គឺ ហុងស៊ូ ហុកកៃដូ ស៊ីកូគូ និងគ្យូស៊ូ។ ជប៉ុនមានផ្ទៃដី ៣៧៣ ០០០ គម²។ ប្រជាជនមាន ១២៣ ០០០ ០០០នាក់ (ឆ្នាំ២០០៨)។ រាជធានី គឺតូក្យូ។ ភាសាផ្លូវការជាភាសាជប៉ុន។ រូបិយវត្ថុគឺយេន។ សព្វថ្ងៃរដ្ឋជប៉ុនជារាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញស្នងរាជ្យ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៦ ចែងថាព្រះចៅអធិរាជមានអំណាចជានិមិត្តរូប។ នាយករដ្ឋមន្ត្រីត្រូវបានជ្រើសតាំងដោយសភា ឬហៅថា ឌីយ៉ែក ដែលមានសភាតំណាងរាស្ត្រដែលមានអាណត្តិរយៈពេល ៤ឆ្នាំ និងព្រឹទ្ធសភាដែលមានអាណត្តិ ៦ឆ្នាំ។

នៅឆ្នាំ១៨៦៧ សូហ្គុនចុងក្រោយ ក៏បានលាលែងពីតំណែង ។ ព្រះចៅអធិរាជមូតស៊ូ ហ៊ិតូ (១៨៦៧-១៩១២) បានមកតាំងរាជធានីនៅតូក្យូ ។

អំឡុងឆ្នាំ១៨៦៨-១៩១២ ហៅថា សម័យមេជី : បច្ចេកទេស និងស្ថាប័នគ្រប់គ្រងតាមរបៀបបស្ចិមប្រទេសត្រូវបានប្រកាន់យក និងប្រែក្លាយជប៉ុនជាមហាអំណាខាងសេដ្ឋកិច្ចនិងនយោបាយ ។ លុះដល់ដើមសង្គ្រាមលោកលើកទីពីរ ប្រទេសជប៉ុន ក៏បានក្លាយខ្លួនជាមហាអំណាចដ៏ខ្លាំងពូកែបំផុតនៅចុងអាស៊ីបូព៌ា ដោយបានគ្រប់គ្រងផ្ទៃកដ៏ធំសម្បើមនៃអាស៊ីអាគ្នេយ៍ ប្រទេសចិនកូរ៉េ និងមហាសមុទ្រប៉ា-ស៊ីហ្វិក ។ ប៉ុន្តែនាខែសីហា ឆ្នាំ១៩៤៥ ជប៉ុនបានចុះចាញ់សង្គ្រាមដោយសារតែមានការទម្លាក់គ្រាប់បែកបរមាណូនៅទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគីពីសំណាក់សហរដ្ឋអាម៉េរិក ។

ទោះជាយ៉ាងណាមកដល់សព្វថ្ងៃ ជប៉ុនក៏នៅតែជាប្រទេសឧស្សាហកម្ម និងអភិវឌ្ឍន៍មួយនាំមុខមួយក្នុងចំណោមប្រទេសខ្លាំងៗនៅលើពិភពលោក ។



## អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

### អ្នកនាំសារ ខែមេសា ២០០៩
### ដោយលោកឪពុករ៉ាំងសង់ សេនីយ៍ឆាល់

**បុណ្យហែស្លឹក និងលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ (ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩)**

(ម៉ាកុស ១៤,១-១៥,៤៧)

ថ្ងៃនេះ គឺជាថ្ងៃចាប់ដើមសប្តាហ៍ពិសិដ្ឋ ។ គ្រីស្តបរិស័ទនាំគ្នារំឭកទៅដល់ព្រះយេស៊ូដែលយាងចូលទៅកាន់ក្រុងយេរូសាលឹម រងទុក្ខលំបាក ហើយក៏សោយទិវង្គតលើភ្នំកុលកូថា ។ បណ្តាលជនអបអរសាទរព្រះអង្គ ប៉ុន្តែម្ខាងទៀតស្រែកថា "ឆ្កាងទៅ!" ។ លោកយូដាសនាំពួកទាហានទៅចាប់ព្រះយេស៊ូដោយសារតែមានចិត្ត លោភលន់ ។ ពួកនាយកបូជាចារ្យបញ្ជូន ព្រះអង្គទៅលោកពីឡាត ពីព្រោះពួកគេមានចិត្តច្រណែន ។ ចំណែកលោកពីឡាតបានកាត់ទោសប្រហារជីវិតព្រះយេស៊ូ ដោយសារតែលោកចង់បំពេញចិត្តបណ្តាជន ។ ដូច្នេះការលំបាកទាំងអស់ដែលព្រះយេស៊ូជួបប្រទះ គ្រាន់តែមកពីអំពើមនុស្សប៉ុណ្ណោះ ។ ប៉ុន្តែព្រះអង្គបានសព្វព្រះហឫទ័យ បូជាព្រះជន្មក្នុងឋានៈជាអ្នកបម្រើព្រះជាម្ចាស់ដើម្បីបង្ហាញច្បាស់ថា មនុស្សត្រូវតែលះបង់អំពើបាប និងអំពើហិង្សាគ្រប់យ៉ាង ។

**បុណ្យចម្លង (ថ្ងៃទី១២ ខែមេសា ២០០៩)**

ម៉ាកុស ១៦,១-៨)

នៅពេលអ្នកដែលត្រូវគេជិះជាន់ស្រែករកព្រះជាម្ចាស់ ព្រះអង្គទ្រង់ព្រះសណ្តាប់សម្រែកនេះ ។ នៅបីថ្ងៃក្រោយពេលព្រះយេស៊ូសោយទិវង្គត គឺនៅថ្ងៃអាទិត្យ ព្រលឹមឡើង ស្ត្រីបីនាក់ក៏ទៅដល់ផ្នូរព្រះអង្គ ប៉ុន្តែពួកគេក៏បានឃើញថា ថ្មបានរមៀលចេញរួចទៅហើយ ហើយកន្លែងនោះនៅទទេ ។ កម្លោះម្នាក់ដែលមានសម្លៀកបំពាក់ពណ៌សប្រាប់គេថា ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឱ្យតើនឡើង នេះមានន័យថា ព្រះជាម្ចាស់ប្រទានឱ្យព្រះយេស៊ូមានព្រះជន្មដ៏រុងរឿងរបស់ព្រះអង្គផ្ទាល់ ។ នេះគឺជាដំណឹងល្អមួយដ៏អស្ចារ្យអំពីព្រះយេស៊ូចំពោះមនុស្សយើង ព្រោះថា ព្រះជាម្ចាស់មិនបោះបង់វិញ្ញាណក្ខន្ធអ្នកបម្រើព្រះអង្គចោលទេ ។ ផ្ទុយទៅវិញព្រះអង្គសព្វព្រះហឫទ័យចែកនូវព្រះជន្មផ្ទាល់របស់ព្រះអង្គ ឱ្យមនុស្សទាំងអស់តាមរយៈព្រះគ្រីស្តដែលយាងទៅស្រុកកាលីឡេមុនពួកសាវ័ក មានន័យថា ព្រះយេស៊ូគឺនៅជាមួយអស់សាវ័ករបស់ព្រះអង្គជារៀងរាល់ថ្ងៃដើម្បីជួយឱ្យគេអាចរស់នៅរបៀបថ្មីនេះ ។

**ថ្ងៃអាទិត្យទី២ នៃរដូវបុណ្យចម្លង ឆ្នាំខ (ថ្ងៃទី១៩ ខែមេសា ២០០៩)**

(យ៉ូហាន ២០,១៩-៣១)

អត្ថបទព្រះគម្ពីរថ្ងៃអាទិត្យនេះចែកចេញជាពីរភាគ គឺក្នុងភាគទី១ ព្រះយេស៊ូដែលមានព្រះជន្មដ៏រុងរឿងបង្ហាញព្រះអង្គឱ្យក្រុមសាវ័ក "ឃើញ" ។ នៅពេលនោះព្រះអង្គផ្លុំលើសាវ័កប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ឱ្យគេ ។ ក្នុងភាគទី២ ប្រាំបីថ្ងៃក្រោយព្រះយេស៊ូសម្តែងព្រះអង្គឱ្យលោកថូម៉ាស "ឃើញ" ព្រោះលោករឹងរូសមិនជឿលើពាក្យសម្តីសាវ័កឯទៀតៗសោះ ។ ចំពោះយើងវិញ មានពេលខ្លះ យើងគិតថា សាវ័កព្រះអង្គមិនពិបាកជឿថា ព្រះយេស៊ូជាព្រះអម្ចាស់ឡើយ ព្រោះពួកគេបានស្គាល់ព្រះអង្គក្នុងលោកនេះ ហើយបានឮព្រះអង្គប្រាប់គេទុកជាមុនអំពីព្រះអង្គរងទុក្ខលំបាក និងអំពីព្រះជន្មអស់កល្បជានិច្ច ។ ប៉ុន្តែសូម្បីលោកថូម៉ាសជាសាវ័កម្នាក់ក៏ដោយ ក៏លោកមិនជឿដែរ! ដូច្នេះ មានន័យថា យើងមិនពិបាកជឿជាងពួកសាវ័កទេ ឬពួកសាវ័កក៏មិនស្រួលជឿជាងយើងដែរ ។ ជំនឿមិនពឹងលើភស្តុតាងទេ ប៉ុន្តែពឹងលើពាក្យសម្តីរបស់គ្រីស្តទូត ។

**ថ្ងៃអាទិត្យទី៣ នៃរដូវបុណ្យចម្លង ឆ្នាំខ (ថ្ងៃទី២៦ ខែមេសា ២០០៩)**

(លូកា ២៤,៣៥-៤៨)

ពេលដែលព្រះយេស៊ូមានព្រះជន្មដ៏រុងរឿងបង្ហាញព្រះអង្គឱ្យក្រុមសាវ័កឃើញ ពួកគេតក់ស្លុតញ័ររន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះស្មានថា ជាខ្មោចលង ។ ប៉ុន្តែព្រះយេស៊ូលើកទឹកចិត្តគេ ហើយធ្វើឱ្យគេទុកចិត្តលើព្រះអង្គវិញ ។ ព្រះយេស៊ូមិនមែនជាខ្មោចទេ! ខ្មោចសុទ្ធតែធ្វើឱ្យមនុស្សភ័យរន្ធត់ តែផ្ទុយទៅវិញព្រះអង្គប្រទានសេចក្តីសុខសាន្តដល់ក្រុមសាវ័ក ។ លើសពីនេះទៅទៀតព្រះយេស៊ូពន្យល់ពួកសាវ័ក ឱ្យគេយល់ថា ពួកគេអាចស្គាល់ព្រះអង្គកាន់តែច្បាស់ឡើងៗ ប្រសិនគេខិតខំអានព្រះគម្ពីរ ធ្វើពិធីកាច់នំប៉័ង និងសន្ទនាជាមួយព្រះអង្គក្នុងការអធិដ្ឋានដោយចិត្តស្មោះនោះ ។

## យើងអាន



Photo: DR

**សួស្តីប្អូនៗ**
**តើប្អូនបានប្រព្រឹត្តខ្លួនរបៀបណាខ្លះដែរក្នុងរដូវអប់រំពិសេសនេះ? ពិធីបុណ្យចម្លងក៏ជិតចូលមកដល់ដែរ។ ប្អូនៗ! មុនចូលដល់បុណ្យចម្លងមួយសប្តាហ៍ តើព្រះសហគមន៍ហៅសប្តាហ៍នេះយ៉ាងដូចម្តេច?**

**ព្រះសហគមន៍ហៅថា នេះជាសប្តាហ៍ពិសិដ្ឋ គឺចាប់ពីថ្ងៃអាទិត្យបុណ្យព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម ឬយើងហៅ "បុណ្យហែស្លឹក"។ ក្នុងសប្តាហ៍នេះ គ្រីស្តបរិស័ទកាតូលិកយកចិត្តទុកដាក់យ៉ាងខ្លាំងលើសកម្មភាពផ្សេងៗ ដែលព្រះយេស៊ូបានប្រព្រឹត្ត ដូចជាថ្ងៃព្រហស្បតិ៍ពិសិដ្ឋ គឺគេប្រារព្ធដើម្បីរំឭកពិធីជប់លៀងរបស់ព្រះយេស៊ូរួមជាមួយក្រុមគ្រីស្តទូត។ ក្នុងពិធីនេះ គឺព្រះយេស៊ូធ្វើពិធីកាច់នំប៉័ង។ មុនកាច់នំប៉័ងព្រះអង្គអរព្រះគុណព្រះបិតា ហើយកាច់ប្រទានទៅគ្រីស្តទូតទាំងមានព្រះបន្ទូលថា: "នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា និងមនុស្សទាំងឡាយ"។ បន្ទាប់មកព្រះយេស៊ូយកពែងស្រាទំពាំងបាយជូរ មកកាន់អរព្រះគុណព្រះបិតា ហើយប្រទានទៅក្រុមគ្រីស្តទូត ទាំងមានព្រះបន្ទូលថា: "សូមយកពែងនេះ ហើយពិសាចុះ។ នេះជាលោហិតរបស់ខ្ញុំដែលចងសម្ពន្ធមេត្រីថ្មី និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរដើម្បីលើកលែងទោសរំដោះបាបឱ្យអ្នករាល់គ្នា និងឱ្យមនុស្សទាំងឡាយ"។ រួចព្រះយេស៊ូបានផ្តាំថា សូមធ្វើដូច្នេះដើម្បីនឹករឭកដល់ព្រះអង្គ។**

**កាយវិការទាំងនេះ គឺព្រះសហគមន៍កាតូលិកបានអនុវត្តមកដល់ថ្ងៃនេះ នៅក្នុងពិធីអភិបូជារៀងរាល់ថ្ងៃអាទិត្យ។ បន្ទាប់ពីជប់លៀងហើយ ព្រះយេស៊ូត្រូវគេចាប់នៅសួនច្បារកេសេម៉ានីដោយសាវ័កយ៉ូដាសអ៊ីស្កាយុតនាំគេមកចាប់ព្រះអង្គ។ នៅថ្ងៃសុក្រពិសិដ្ឋ គឺរំឭកអំពីទុក្ខលំបាករបស់ព្រះយេស៊ូដែលត្រូវគេឆ្កាងរហូតដល់សោយទិវង្គត។ រហូតដល់រាត្រីថ្ងៃសៅរ៍ពិសិដ្ឋព្រះជាម្ចាស់ប្រោសព្រះយេស៊ូឱ្យមានព្រះជន្មថ្មីដ៏រុងរឿង គឺបុណ្យចម្លងនេះឯង មានន័យថា ឆ្លងពីសេចក្តីស្លាប់ទៅរកជីវិតថ្មីដ៏រុងរឿង។**

**លី សុវណ្ណា**

April-2009.qxd 3/25/2009 4:08 PM Page 20

# កំប្លែង និងពាក្យបណ្ដៅ

**កំប្លែង**

- ឯងសាកទាយលមើល៍ តើមានស្កគ្រាប់ប៉ុន្មាននៅក្នុងដៃខ្ញុំ។ បើឯងទាយត្រូវ ខ្ញុំអោយឯងទាំងពីរគ្រាប់។
- មានស្ករពីរគ្រាប់។
- ចុះឯងពូកែទាយម្ល៉េះ!

**ពាក្យបណ្ដៅ**

សត្វអីមានជើង៦ ហើយវានៅលើក្បាល?

ចំលើយ : សត្វចៃ

**កំប្លែង**

- ថ្ងៃនេះ ពេលធ្វើសំនួរសរសេរគណិត ខ្ញុំប្រាកដជាបានសូន្យហើយ។
- ចុះម៉េចក៏ឯងប្រាកដម្ល៉េះ?
- ខ្ញុំប្រាកដដូចជា ២គុណ២ ស្មើ ៥ អ៊ីចឹង។

**ពាក្យបណ្ដៅ**

តើសត្វអីមានបីពណ៌ ក្រហម លឿង បៃតង តែងឈរនៅផ្លូវបែកជាបួន?

ចំលើយ : ភ្លើងស្តុប

**ពាក្យបណ្ដៅ**

តើប្រទេសណាមិននៅជាប់ប្រទេសកម្ពុជា?
- ❖ ប្រទេសថៃ
- ❖ ប្រទេសជប៉ុន
- ❖ ប្រទេសវៀតណាម

ចំលើយ : ប្រទេសជប៉ុន

**ពាក្យបណ្ដៅ**

តើអ្វីដែលធំប៉ុននឹង វិមានឯករាជ្យ តែមានទំងន់ស្មើនឹង ០គីឡូក្រាម?

ចំលើយ : ស្រមោលរបស់វា

**កំប្លែង**

- អាឡូអ្នកគ្រូ ថ្ងៃនេះ តុំអត់បានទៅរៀនទេ!
- ចុះនរណាទូរស័ព្ទមកហ្នឹង?
- គឺពុកខ្ញុំ។

**ពាក្យបណ្ដៅ**

ខ្ញុំនៅផ្ទះអ្នក ខ្ញុំនៅផ្ទះគេគ្រប់គ្នា តែនៅពេលគេបង្វិលក្បាលខ្ញុំ ខ្ញុំយំហើយ។ តើខ្ញុំជាអ្វី?

ចំលើយ : ក្បាលរ៉ូប៊ីណេទឹក

**កំប្លែង**

- តុំ ម៉េចក៏តែងសេចក្ដីអំពីដើមត្នោតរបស់ឯងដូចតែងសេចក្ដីរបស់តុលបេះបិទអ៊ីចឹង?
- មកពីពួកយើងសរសេរពីដើមត្នោតតែមួយ។

សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។

អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ-កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

## កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

ជាកម្មវិធីមួយដែលរៀបចំឡើងដោយការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ក្នុងការបង្ហាញផ្លូវ និងរកដំណោះស្រាយដល់មិត្តយុវវ័យ មានដូចជាបញ្ហាសង្គម ចិត្តសាស្ត្រ និងទំនាក់ទំនងយុវវ័យ-ល-។ កម្មវិធីនេះមានការផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ និងអង្គារ វេលាម៉ោង ១០-១១ព្រឹក នៅវិទ្យុគ្រួសារ **FM 99.5 Mhz** រាជធានីភ្នំពេញ។

## ការងារប្រចាំខែ

- ថ្ងៃទី១ មេសា : ប្រជុំអភិបាលទាំងបីភូមិភាគ និងតំណាងពេញសិទ្ធិនៅកំពង់ចាម។
- ថ្ងៃទី០១ មេសា : ប្រជុំក្រុមប្រឹក្សាភូមិភាគភ្នំពេញនៅព្រះវិហារផ្សារតូចចំនួន ៣០នាក់។
- ថ្ងៃទី២ មេសា : ការប្រារព្ធពិធីប្រសិទ្ធពរលើប្រេង នៅព្រះសហគមន៍សន្តយ៉ូសែប ហៅផ្សារតូច នៅរាជធានីភ្នំពេញ។
- ថ្ងៃទី០៨ មេសា : ព្រះសហគមន៍ផ្សារតូចចែកអង្ករដល់ជូនក្រីក្រចំនួន ១០០គ្រួសារ។
- ថ្ងៃទី៩-១១ មេសា : សំណាក់ធម៌របស់ក្រុមវ៉ាំងសង់ ឌីប៉ូល នៅពោធិ៍សាត់ និងរិះគិតប្រធានបទ "ទំនាក់ទំនងជាមួយព្រះជាម្ចាស់"។
- ថ្ងៃទី១១ មេសា : ជ្រមុជទឹកដល់អ្នកត្រៀមចំនួន ៩នាក់ នៅព្រះសហគមន៍កំពង់សោម។
- ថ្ងៃទី១១ មេសា : ពិធីបុណ្យជ្រមុជទឹកដល់យុវជនចំនួន ២០នាក់ នៅព្រះសហគមន៍កាតូលិកសៀមរាប ក្រោមការដឹកនាំ និងថ្វាយអភិបូជាពីលោកបូជាចារ្យហេរី។
- ថ្ងៃទី១១ មេសា : ជ្រមុជទឹកដល់អ្នកត្រៀមចំនួន ១៦នាក់ នៅព្រះវិហារខេត្តកំពត។ លោកបូជាចារ្យអ៊ុន ស៊ុន ជាអ្នកថ្វាយអភិបូជា។
- ថ្ងៃទី១១ មេសា : ពិធីបុណ្យជ្រមុជទឹកនៅព្រះវិហារសន្តយ៉ូសែបផ្សារតូច សម្រាប់អ្នកត្រៀមចំនួន ៨នាក់ និងថ្វាយអភិបូជាដោយលោកអភិបាលភូមិភាគភ្នំពេញអេមីល ដេតម្បេ។
- ថ្ងៃទី១២ មេសា : ពិធីបុណ្យចូលឆ្នាំខ្មែរ និងស្រូចទឹកជូនដល់មនុស្សចាស់នៅកំពង់ចាម។
- ថ្ងៃទី១៧ មេសា : សម្ពោធព្រះវិហារនៅព្រះសហគមន៍កោះរកា ភូមិភាគកំពង់ចាមដោយលោកអភិបាលអន់ទួនី។
- ថ្ងៃទី១៩-២៤ មេសា : សិក្ខាសាលាសម្រាប់គ្រូអប់រំជំនឿ និងការណែនាំដោយអង្គការការ៉ូ និងសេម្ហានៅ ខេត្តកំពង់សោម។
- ថ្ងៃទី២៥-២៦ មេសា : សិក្ខាសាលាដល់ក្រុមយុវជនភូមិភាគភ្នំពេញ ស្ដីអំពីការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលរៀបចំធ្វើឡើងនៅព្រះសហគមន៍បឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី២៧ មេសា : ពិធីថ្វាយអភិបូជានៅស្រុកមេមត់រៀបចំដោយលោកជីពុកសេរ៉ាល់ដ៍។
- ថ្ងៃទី១-៣ ឧសភា : កម្មវិធីសំណាក់ធម៌របស់ក្រុមវ៉ាំងសង់ ឌីប៉ូល និងរិះគិតលើកប្រធានបទ "ហេតុអ្វីត្រូវជួយអ្នកក្រីក្រ?" ដែលមានអ្នកចូលរួម ៥០នាក់ នៅកំពង់សោម។